00424654

C20/9/2

**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អបជ ៣៣)

ភាគីដាក់ឯកសារ: ការិយាល័យសហព្រះរាជអាជ្ញា

ដាក់ជូន: អង្គបុរេជំនុំជម្រះ

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១០

ឯកសារដើម
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 08 / JAN / 2010
ម៉ោង (Time/Heure): 15:20
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ: សម្ងាត់ Public (Redacted Version)

ចំណាត់ថ្នាក់ឯកសារដោយ កសចស សាធារណៈ / Public

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 11 / JAN / 2010
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: [signature]

---

**(អត្ថបទដែលបានលុបចេញផ្នែកខ្លះ)**

**ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាសម្រេចពន្យារចិរវេលាបន្ថែមនៃការឃុំខ្លួនជនត្រូវចោទបណ្តោះអាសន្ន របស់ការិយាល័យសហចៅក្រមស៊ើបអង្កេត**

---

**ដាក់ដោយ៖**

**សហព្រះរាជអាជ្ញា**

ជា លាង

Andrew CAYLEY

យ៉ែត ចរិយា

William SMITH

សេង ប៊ុនឃាង

Vincent de WILDE d'ESTMAEL

**ផ្ញើជូន៖**

**ចៅក្រមអង្គបុរេជំនុំជម្រះ**

ចៅក្រម ប្រាក់ គឹមសាន ជាប្រធាន

ចៅក្រម ន័យ ថុល

ចៅក្រម ហួត វុទ្ធី

ចៅក្រម Katinka LAHUIS

ចៅក្រម Rowan DOWNING

**ជនត្រូវចោទ និង មេធាវីការពារក្តី៖**

**អៀង ធីរិទ្ធ**

**ផាត់ ពៅស៊ាង**

Diana ELLIS

**នួន ជា**

**សុន អរុណ**

Michiel PESTMAN

**អៀង សារី**

**អាង ឧត្តម**

Michael G. KARNAVAS

**ខៀវ សំផន**

**ស ស្វាន**

Jacques VERGES

**កាំង ហ្កេកអ៊ាវ ហៅ ឌុច**

**ការ សាវុត្ថ**

François ROUX
Marie-Paule CANIZARES

**មេធាវីតំណាងដើមបណ្តឹង រដ្ឋប្បវេណី៖**

**គីម ម៉េងឃី**

**ម៉ុច សុវណ្ណារី**

Martine JACQUIN
Phillipe CANONNE
Elizabeth RABESANDRATANA
Annie DELAHAIE
Fabienne TRUSSES-NAPROUS

**នី ចាន់ឌី**

**ឡោ ជុនធី**

Silke STUDZINSKY

**គង់ ពិសី**

**ហុង គីមស្អួន**

**យុង ផានិត**

**ស៊ិន ស៊ីវ៉ន**

Mahdev MOHAN
NGUYEN Lyma
Marie GUIRAUD
Patrick BAUDOIN
Olivier BAHOUGNE
David BLACKMAN

# I. សេចក្តីផ្តើម

1. សហព្រះរាជអាជ្ញាឆ្លើយតបទៅនឹងពាក្យបណ្តឹងរបស់ក្រុមមេធាវីការពារក្តី ("ពាក្យបណ្តឹង") ដែលបានដាក់កាលពីថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០០៩[1] អនុលោមតាមវិធាន ៧៤(ខ) និង ៧៥ នៃវិធានផ្ទៃក្នុង ("វិធាន") និងបានជូនដំណឹងដល់ភាគីនានាកាលពីថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៩[2]។ បណ្តឹងឧទ្ធរណ៍ស្នើសុំអង្គបុរេជំនុំជម្រះ ("អបជ") ឱ្យទុកជាមោឃៈនូវដីការបស់សហចៅក្រមស៊ើបអង្កេតសម្រេចបន្តថិរវេលានៃការឃុំខ្លួន អៀង ធីរិទ្ធ ("ជនត្រូវចោទ" ឬ "ដើមបណ្តឹងឧទ្ធរណ៍") បណ្តោះអាសន្ន[3] ("ដីកាសម្រេចពន្យារថិរវេលាឃុំខ្លួនលើកទីពីរ") និងសុំឱ្យដោះលែងគាត់ឱ្យបានឆាប់នៅក្រោមលក្ខខណ្ឌសមស្រប។ ក្រុមមេធាវីការពារក្តីលើកឡើងថា (i) សហចៅក្រមស៊ើបអង្កេត ("សចស") បានកំណត់អំពីលក្ខខណ្ឌកំណត់នៃវិធាន ៦៣ នៃវិធានផ្ទៃក្នុង មិនបានត្រឹមត្រូវនោះទេ ពីព្រោះសហចៅក្រមស៊ើបអង្កេតកំពុងអនុវត្តតាម "គោលនយោបាយនៃការបន្តការឃុំខ្លួនបណ្តោះអាសន្នដោយស្វ័យប្រវត្តិ" ដោយគ្មានការវាយតម្លៃច្បាស់លាស់អំពីលក្ខខណ្ឌកំណត់ដែលប្រើប្រាស់នូវបទដ្ឋាននៃកិច្ចខិតខំប្រឹងប្រែងពិសេស នៅពេលដែលការស៊ើបអង្កេតបានឈានមកដល់ទីបញ្ចប់នោះទេ (ii) គ្មានហេតុផលដែលត្រូវបានរកឃើញនិងជឿជាក់បានថា ជនត្រូវចោទបានប្រព្រឹត្តបទឧក្រិដ្ឋនោះទេ ដោយសារតែ សចស គ្មានភាពអនាគតិ និងបានធ្វើការថ្លឹងថ្លែងលើភស្តុតាងដាក់បន្ទុកខ្លាំងជាង និងមិនយកចិត្តទុកដាក់ចំពោះភស្តុតាងដោះបន្ទុកនោះឡើយ (iii) ដីកាសម្រេចពន្យារថិរវេលាឃុំខ្លួនលើកទីពីរ មិនបានបង្ហាញនូវ "ហានិភ័យពិតប្រាកដ" ណាមួយដែលថា ជនត្រូវចោទនឹងគាបសង្កត់លើសាក្សី ឬបំផ្លាញភស្តុតាងនោះទេ ប្រសិនបើត្រូវបានដោះលែងនោះ ជាពិសេសនៅពេលបិទការស៊ើបសួរ (iv) ដីកាសម្រេចពន្យារថិរវេលាឃុំខ្លួនលើកទីពីរ មិនបានបង្ហាញនូវហានិភ័យណាមួយដែលថា ជនត្រូវចោទនឹងរត់គេចខ្លួននោះទេ ប្រសិន បើត្រូវបានដោះលែងនោះ ហានិភ័យនេះគ្មានលក្ខណៈគួរឱ្យកត់សម្គាល់នោះទេ ផ្អែកតាមស្ថានភាពសុខភាព

---

[1] *រឿងក្តី អៀង ធីរិទ្ធ,* បណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តីប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស អំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នលោកស្រី អៀង ធីរិទ្ធ, ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០០៩, ឯកសារ C20/9/1, ERN 00411092-102 (ភាសាអង់គ្លេស)។

[2] នៅក្នុងអនុស្សារណអន្តរការិយាល័យ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៩, (ERN 00403591 -ភាសាអង់គ្លេស-), អង្គបុរេជំនុំជម្រះបានផ្តល់ព័ត៌មានដល់ភាគីទាំងឡាយថា ពួកគេនឹងមានការឈប់សម្រាកក្នុងអំឡុងពេលនៃថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០០៩ ដល់ថ្ងៃទី៤ ខែមករា ឆ្នាំ២០១០។ ជាលទ្ធផល ចម្លើយតបបណ្តឹងឧទ្ធរណ៍នេះ ត្រូវបានដាក់នៅថ្ងៃទី៥ ខែមករា ឆ្នាំ២០១០ គឺជាថ្ងៃធ្វើការបន្តបន្ទាប់។

[3] *រឿងក្តី អៀង ធីរិទ្ធ,* ដីកាសម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន, ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៩, ឯកសារ C20/8, ERN 00399346-357 (ភាសាអង់គ្លេស) បន្ទាប់ពីនេះ "ដីកាអំពីការបន្តថិរវេលា"។

របស់ជនត្រូវចោទ (v) ដីកាសម្រេចពន្យារថិរវេលាឃុំខ្លួនលើកទីពីរ មិនបានបង្ហាញនូវ "ហានិភ័យពិតប្រាកដ" ណាមួយ ស្តីពីការរំខានដល់សណ្តាប់ធ្នាប់សាធារណៈនោះទេ នៅថ្ងៃអនាគត ប្រសិនបើជនត្រូវចោទត្រូវបានដោះលែងនោះ។

2. សហព្រះរាជអាជ្ញា ស្នើសុំឱ្យអង្គបុរេជំនុំជម្រះបដិសេធបណ្តឹងឧទ្ធរណ៍ ដោយសារមូលហេតុជាច្រើនដូចខាងក្រោម:

(ក) ដីកាសម្រេចពន្យារថិរវេលានៃការឃុំខ្លួនលើកទីពីរចេញដោយ សចស បានផ្តល់មូលហេតុគ្រប់គ្រាន់ និងពេញលេញរួចហើយ ដោយ សចស បានធ្វើការពិចារណាលើមូលដ្ឋានច្បាប់ និង អង្គហេតុនានាមុនពេលចេញដីកាសម្រេចពន្យារថិរវេលានៃការឃុំខ្លួនលើកទីពីរ និងគ្មានកាតព្វកិច្ចក្នុងការបង្ហាញអំពីការយល់ឃើញលើកត្តាទាំងអស់នោះឡើយ។ ពុំមានគោលនយោបាយនៃការបន្តការឃុំខ្លួនបណ្តោះអាសន្នជាស្វ័យប្រវត្តិនោះទេ ប៉ុន្តែមានការពិនិត្យឡើង វិញចំពោះការឃុំខ្លួនជនត្រូវចោទបណ្តោះអាសន្ន តាមពេលវេលាកំណត់ទៀងទាត់ជាស្វ័យប្រវត្តិដែលជាការគោរពដល់សិទ្ធិនានារបស់ក្រុមមេធាវីការពារក្តី និងជាផលប្រយោជន៍របស់ជនត្រូវចោទ។

(ខ) រយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្នមានភាពសមស្រប និងគ្មានកង្វះកិច្ចខិតខំប្រឹងប្រែងពីភ សចស នៅក្នុងការដឹកនាំកិច្ចដំណើរការនីតិវិធីនោះទេ។

(គ) ការលើកឡើងរបស់ក្រុមមេធាវីការពារក្តីដែលថា សចស "បានខកខានមិនបានបំពេញកិច្ចប្រកបដោយភាពអនាគតិ និងបានខកខានមិនបានវាយតម្លៃភស្តុតាងឱ្យបានត្រឹមត្រូវ និងយុត្តិធម៌នោះ" គឺគ្រាន់តែជាការលើកឡើងដើម្បីជំទាស់ចំពោះប្រតិបត្តិការរបស់ សចស ដែលពុំមានចំណុចណាមួយ ត្រូវបានអង្គបុរេជំនុំជម្រះរកឃើញថាមានសុពលភាពនោះទេ។ ទឡ្ហីករណ៍តូចតាច ដែល សចស វិនិច្ឆ័យលើភស្តុតាងដាក់បន្ទុក និងភស្តុតាងដោះបន្ទុកដោយប្រើប្រាស់ បទដ្ឋានខុសគ្នានោះ មិនបានធ្វើឱ្យភស្តុតាងដ៏ច្រើនលើសលុបដែលមានកន្លងមកនោះអស់សុពលភាព និងលែងមានយុត្តិកម្មលើការឃុំខ្លួនជនត្រូវចោទ ស្របតាមវិធាន ៦៣(៣)(ក) នៃវិធានផ្ទៃក្នុងនោះទេ។

(ឃ) ដើមបណ្តឹងឧទ្ធរណ៍ខកខានមិនបានបង្ហាញអំពីការប្រែប្រួលសត្យានុម័ត នៅក្នុងកាលៈទេសៈនានាចាប់តាំងពីគាត់ត្រូវបានឃុំខ្លួនដំបូងដោយ សចស កាលពីថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៧

("ដីកាសម្រេចឃុំខ្លួនដំបូង")[4]។ លើសពីនេះទៀត គាត់នៅតែខកខានមិនបានបង្ហាញចំណុចនេះទៀត ចាប់តាំងពីការឃុំខ្លួននោះត្រូវបានបញ្ជាក់ដោយអង្គបុរេជំនុំជម្រះ កាលពីថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០០៨[5] ចាប់តាំងពីមានការសម្រេចពន្យារចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នលើកទីមួយ កាលពីថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៨[6] និងចាប់តាំងពីដីកានោះត្រូវបានបញ្ជាក់ដោយអង្គបុរេជំនុំជម្រះ កាលពីថ្ងៃទី១១ ខែឧសភា ឆ្នាំ២០០៩[7] មកម្ល៉េះ។ នៅក្នុងសេចក្តីសម្រេចក្រោយមកទៀត អបជ បានរៀបរាប់លម្អិតអំពីភស្តុតាងដាក់បន្ទុក និងបានកត់សម្គាល់ឃើញថា ភស្តុតាងដែលអាចមានលក្ខណៈដោះបន្ទុកនៅក្នុងសំណុំរឿងមិនបានប៉ះពាល់ដល់សេចក្តីសន្និដ្ឋានកាលពីមុនរបស់ អបជ ដែលថា សចស មានយុត្តិកម្ម ក្នុងការបង្ហាញថា វាមានមូលហេតុដែលត្រូវបានរកឃើញដើម្បីឱ្យជឿថា ជនត្រូវចោទមានការទទួលខុសត្រូវចំពោះបទឧក្រិដ្ឋ ដែលគាត់ត្រូវបានចោទប្រកាន់[8]។

(ង) លក្ខខណ្ឌនានាសម្រាប់ការឃុំខ្លួនបណ្តោះអាសន្ន នាបច្ចុប្បន្ននេះនៅតែត្រូវបានបំពេញ សំណុំរឿងមានភស្តុតាងដែលអាចធ្វើឱ្យអ្នកសង្កេតការណ៍សត្យានុម័តជឿជាក់ថា ដើមបណ្តឹងឧទ្ធរណ៍បានប្រព្រឹត្តបទឧក្រិដ្ឋនានា ដែលរូបគាត់កំពុងស្ថិតនៅក្រោមការស៊ើបអង្កេត នាបច្ចុប្បន្ននេះ (វិធាន ៦៣(៣)(ក) នៃវិធានផ្ទៃក្នុង)។ ភស្តុតាងជាច្រើនត្រូវបានបន្ថែមចូលក្នុងសំណុំរឿង ចាប់តាំងពីខែកុម្ភៈ ឆ្នាំ២០០៩ រីឯភស្តុតាងបន្ថែមនិងជាក់លាក់ ត្រូវបានដាក់ចូលក្នុងសំណុំរឿង បន្ទាប់ពីការចេញដីកាសម្រេចពន្យារចិរវេលាឃុំខ្លួនលើកទីពីរ ដែលនាំឱ្យ សចស ជូនដំណឹងអំពីការចោទប្រកាន់បន្ថែម ដល់ដើមបណ្តឹងឧទ្ធរណ៍ កាលពីថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៩។ បន្ថែមលើនេះទៀត យ៉ាងហោចណាស់មានលក្ខខណ្ឌចំនួនបួនក្នុងចំណោម

---

[4] *រឿងក្តី អៀង ធីរិទ្ធ,* ដីកាបង្គាប់ឱ្យឃុំខ្លួន, ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៧, ឯកសារ C21, ERN 00153250-52 (ភាសាអង់គ្លេស)។

[5] *រឿងក្តី អៀង ធីរិទ្ធ,* សាលដីការបស់ អ.ប.ជ លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទ អៀង ធីរិទ្ធ, ចុះថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០០៨, ឯកសារ C20/I/26, ERN 00201588-604 (ភាសាអង់គ្លេស), បន្ទាប់ពីនេះ "សាលដីកាលើបណ្តឹងឧទ្ធរណ៍ឃុំខ្លួនបណ្តោះអាសន្ន"។

[6] *រឿងក្តី អៀង ធីរិទ្ធ,* ដីកាសម្រេចអំពីការបន្តចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នរបស់ សចស, ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០០៨, C20/4, ERN 00238528-36 (ភាសាអង់គ្លេស), បន្ទាប់ពីនេះ "ដីកាសម្រេចបន្តចិរវេលាលើកទីមួយ"។

[7] *រឿងក្តី អៀង ធីរិទ្ធ,* សាលដីការបស់ អ.ប.ជ លើបណ្តឹងឧទ្ធរណ៍របស់លោកស្រី អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាសម្រេចអំពីការបន្តចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន, ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០០៩, ឯកសារ C20/5/17, ERN 00303491-510 (ភាសាអង់គ្លេស), បន្ទាប់ពីនេះ "សាលដីកាលើបណ្តឹងឧទ្ធរណ៍អំពីការបន្តចិរវេលាលើកទីមួយ"។

[8] សាលដីកាលើបណ្តឹងឧទ្ធរណ៍អំពីការបន្តចិរវេលាលើកទីមួយ, កថាខណ្ឌ២៩។

00424659



លក្ខខណ្ឌទាំងប្រាំយ៉ាង ដែលចែងក្នុងវិធាន ៦៣(៣)(ខ) នៅតែត្រូវបានបំពេញ និងត្រូវបានធ្វើឱ្យមានលក្ខណៈរឹងមាំកាន់តែខ្លាំង តាមរយៈឧប្បត្តិហេតុថ្មីៗមួយចំនួន នៅមន្ទីរឃុំឃាំង និងនៅក្នុងពេលស្សរដេញដោល ដែលតាមរយៈនោះនាំឱ្យការឃុំខ្លួនបណ្ដោះអាសន្ន ក្លាយជាវិធានការដ៏ចាំបាច់។ ជាពិសេស ការឃុំខ្លួន នៅតែមានភាពចាំបាច់ ដើម្បី (i) ការពារជនត្រូវចោទកុំឱ្យមានការគាបសង្កត់ទៅលើសាក្សី និងជនរងគ្រោះ (ii) ថែរក្សា ភស្តុតាង និងការពារកុំឱ្យមានការបំផ្លាញភស្តុតាង (iii) ធានាអំពីវត្តមានរបស់ជនត្រូវចោទនៅក្នុងកិច្ចដំណើរការនីតិវិធី និង (iv) រក្សាសណ្ដាប់ធ្នាប់សាធារណៈ។

## II. ប្រវត្តិនីតិវិធី

3. នៅថ្ងៃទី១១ ខែឧសភា ឆ្នាំ២០០៨ អបជ បានចេញសេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍របស់ក្រុមមេធាវីការពារក្ដីប្រឆាំងនឹងដីកាសម្រេចបន្តចិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន[9]។

4. នៅថ្ងៃទី៥ ខែតុលា ឆ្នាំ២០០៨ អនុលោមតាមវិធាន ៦៣(៧) នៃវិធានផ្ទៃក្នុង សចស បានជូនដំណឹងដល់ជនត្រូវចោទ និងមេធាវីរបស់គាត់ថា សចស បាននឹងកំពុងពិចារណាអំពីការបន្តចិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន[10] និងបានស្នើសុំឱ្យជនត្រូវចោទនិងមេធាវីរបស់គាត់ដាក់ការសង្កេតរបស់ខ្លួននៅក្នុងរយៈពេល១៥ថ្ងៃ ដែលជនត្រូវចោទនិងមេធាវីរបស់គាត់បានធ្វើ កាលពីថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៨[11]។ នៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៨ សចស បានចេញដីកាសម្រេចបន្តចិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នលើកទី២[12]។ នៅថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០០៨ ក្រុមមេធាវីការពារក្ដី បានដាក់ពាក្យបណ្ដឹងឧទ្ធរណ៍លើកទី២ប្រឆាំងនឹងដីកាសម្រេចបន្តចិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន ដែលត្រូវបានជូនដំណឹងដល់ភាគីនានា កាលពីថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៨ និងត្រូវបានសហព្រះរាជអាជ្ញា ឆ្លើយតបទៅនឹងពាក្យបណ្ដឹងនេះ។

---

[9] សាលដីកាលើបណ្ដឹងឧទ្ធរណ៍អំពីការបន្តចិរវេលាលើកទីមួយ។

[10] *រឿងក្ដី អៀង ធីរិទ្ធ,* សេចក្ដីជូនដំណឹងរបស់សហចៅក្រមស៊ើបអង្កេត ចំពោះលោកស្រី អៀង ធីរិទ្ធ និង មេធាវីរបស់គាត់ទាក់ទងនឹងទស្សនៈរបស់ពួកគេលើការបន្តចិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន, ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ២០០៨, ឯកសារ C20/6, ERN 00385005-6 (ភាសាអង់គ្លេស)។

[11] *រឿងក្ដី អៀង ធីរិទ្ធ,* ការសង្កេតរបស់ក្រុមមេធាវីការពារក្ដីលើចេតនារបស់សហចៅក្រមស៊ើបអង្កេតក្នុងការពន្យារចិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នអ្នកស្រី អៀង ធីរិទ្ធ, ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៨, ឯកសារ C20/7, ERN 00390229-242 (ភាសាអង់គ្លេស)។

[12] ដីកាសម្រេចបន្តចិរវេលាលើកទីមួយ។

5. នៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៨ សចស បានជូនដំណឹងអំពីការចោទប្រកាន់បន្ថែមដល់ជនត្រូវចោទ បន្ថែមលើឧក្រិដ្ឋកម្មនានាប្រឆាំងនឹងមនុស្សជាតិៈ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ និងបទឧក្រិដ្ឋថ្នាក់ជាតិនានា[13]។

## III. ច្បាប់

### *លក្ខខណ្ឌនានាដែលតម្រូវឱ្យមានសម្រាប់ការឃុំខ្លួនបណ្ដោះអាសន្ន*

6. ស្របតាមវិធាន ៦៣(៣) នៃវិធានផ្ទៃក្នុង សចស អាចចេញដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន នៅពេលដែលៈ

ក- មានមូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់ថា ជននោះធ្លាប់បានប្រព្រឹត្តបទល្មើសនានាដូចមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ និង

ខ- សហចៅក្រមស៊ើបអង្កេតពិចារណាឃើញថា ការឃុំខ្លួនបណ្ដោះអាសន្ន គឺជាវិធានការដ៏ចាំបាច់ ដើម្បីៈ

(១) រារាំងកុំឱ្យជនដែលត្រូវចោទនោះគាបសង្កត់ទៅលើសាក្សី ឬជនរងគ្រោះ ឬរារាំងកុំឱ្យមានការត្រូវរូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិត។

(២) ថែរក្សាភស្តុតាង ឬការពារមិនឱ្យបំផ្លាញភស្តុតាង។

(៣) ធានាអំពីវត្តមានរបស់ជនត្រូវចោទនៅក្នុងដំណើរការនីតិវិធី។

(៤) ការពារសន្តិសុខឱ្យជនដែលត្រូវចោទ ឬ

(៥) រក្សាសណ្ដាប់ធ្នាប់សាធារណៈ"។

7. មូលដ្ឋាននៃការឃុំខ្លួនចំនួនប្រាំយ៉ាង ស្របតាមវិធាន ៦៣(៣)(ខ) គឺជាមូលដ្ឋានដាច់ដោយឡែកពីគ្នា ហេតុដូច្នេះហើយ ពុំមានលក្ខខណ្ឌកំណត់ថា សចស យល់ឃើញថា គ្រប់មូលដ្ឋានទាំងអស់ត្រូវបានបំពេញមុនពេល សចស ពិចារណាថា ការឃុំខ្លួនបណ្ដោះអាសន្នគឺជាវិធានការដ៏ចាំបាច់ ឬថា ការបន្តចិរវេលាឃុំខ្លួនត្រូវបានធានាអះអាងនោះទេ។ ផ្ទុយទៅវិញ ប្រសិនបើ សចស ពិចារណាឃើញថា មានមូលដ្ឋានណាមួយក្នុងចំណោមមូលដ្ឋានទាំងប្រាំយ៉ាងនោះមានអត្ថិភាព ការវិនិច្ឆ័យអំពីការឃុំខ្លួនត្រូវបានបំពេញរួចហើយ។ វិធីសាស្ត្រនេះក៏ត្រូវបានអនុវត្តតាមផងដែរដោយតុលាការ

---

[13] *រឿងក្តី អៀង ធីរិទ្ធ,* កំណត់ហេតុរបស់ ក.ស.ច.ស នៃការសួរចម្លើយជនត្រូវចោទ, ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៨, ឯកសារ D286, ERN 00418007-12 (ភាសាអង់គ្លេស)។

ព្រហ្មទណ្ឌផ្សេងទៀតដែលពាក់ព័ន្ធជាមួយនឹងបទឧក្រិដ្ឋអន្តរជាតិធ្ងន់ធ្ងរនានា ដែលមានលក្ខណៈស្រដៀងគ្នា[14]។

### *លក្ខណៈ និងវិសាលភាពនៃការពិនិត្យឡើងវិញរបស់អង្គបុរេជំនុំជម្រះ*

8. បញ្ហាសំខាន់នៅក្នុងការកំណត់សម្រេចអំពីបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាសម្រេចបន្តចិរវេលាឃុំខ្លួន គឺថា តើលក្ខខណ្ឌនានាដែលបានកំណត់នៅក្នុងវិធាន ៦៣(៣) នៅតែត្រូវបានបំពេញដែរឬទេ។ ក្រុមមេធាវីការពារក្តីហាក់ដូចជាបានយល់ច្រឡំអំពីលក្ខណៈ និងវិសាលភាពនៃការពិនិត្យឡើងវិញ របស់ អបជ នៅពេលដែល អបជ បានទទួលបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់សចស។ នៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ អបជ មិនបានដើរតួនាទីជា "តុលាការកំពូល" (*cour de cassation*) ដែលនឹងទុកជាមោឃៈនូវដីកា និងបញ្ជូនដីកានោះទៅ សចស នោះទេ។ អបជ អាចជំនួសដីការបស់ សចស ដោយសេចក្តីសម្រេចផ្ទាល់របស់ខ្លួន និងដាក់ជំនួសនូវមូលហេតុនិងអំណះអំណាងផ្ទាល់របស់ខ្លួន តបទៅនឹងមូលហេតុនិងអំណះអំណាងរបស់ សចស[15]។ នៅក្នុងករណីមានការមិនគោរពវិធានបញ្ញត្តិ អបជ មានឆន្ទានុសិទ្ធិក្នុងការ "ធ្វើសេចក្តីវិភាគផ្ទាល់របស់ខ្លួនដោយអនុវត្តបទដ្ឋានដែលបានកំណត់នៅក្នុងវិធាន ៦៣(៣) នៃវិធានផ្ទៃក្នុង"[16] និងបញ្ឈប់នូវការមិនគោរពវិធានបញ្ញត្តិ តាមរយៈការដាក់ជំនួសមូលហេតុផ្ទាល់របស់អបជ[17]។ លើសពីនេះទៀត អបជ មិនត្រូវធ្វើការពិនិត្យសំណុំរឿង និងលក្ខខណ្ឌនានានៃវិធាន ៦៣(៣) នៃវិធានផ្ទៃក្នុង

---

[14] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Sainovic និង Odjanic,* ដីកាសម្រេចបដិសេធការស្នើសុំប្តឹងឧទ្ធរណ៍របស់ Ojdanic, រឿងក្តីលេខ IT-99-37-AR65.2, អង្គជំនុំជម្រះតុលាការកំពូល ICTY, ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០៣, ទំព័រ៣, ត្រូវបានទទួលយកដោយ អ.វ.ត.ក-អ.ប.ជ ក្នុងរឿងក្តី កាំង ហ្គេកអ៊ាវ ហៅ "ឌុច", សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទ កាំង ហ្គេកអ៊ាវ ហៅ "ឌុច", សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក-ក.ស.ច.ស (អ.ប.ជ០១), ចុះថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០០៧, ERN 00154284-302, ឯកសារ C5/45, កថាខណ្ឌ ៥៩ ។

[15] តាមពិត អ.ប.ជ ថ្លែងថា "*ការតម្កល់ឃុំខ្លួនរបស់សហចៅក្រមស៊ើបអង្កេត ហើយមូលហេតុដែលបញ្ជាក់ក្នុងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នរបស់សហចៅក្រមស៊ើបអង្កេត ត្រូវបានជំនួសដោយមូលហេតុដែលបានបញ្ជាក់ក្នុងសាលដីកានេះ*"។ ជាឧទាហរណ៍, សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទ អៀង ធីរិទ្ធ,ឯកសារ C20/I/26, ERN 00201588-604 (ភាសាអង់គ្លេស), ត្រង់ ERN 00201604 (សម្រេច, កថាខណ្ឌចុងក្រោយ)។

[16] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទ អៀង ធីរិទ្ធ,ឯកសារ C20/I/26, ERN 00201588-604 (ភាសាអង់គ្លេស), ត្រង់ ERN 00201592, កថាខណ្ឌ១៨។

[17] អ.ប.ជ បានថ្លែងក្នុងកថាខណ្ឌ៤២ នៃ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទ អៀង ធីរិទ្ធ (C20/I/26, ត្រង់ ERN 00201598), ថា "*អង្គបុរេជំនុំជម្រះបានសង្កេតឃើញទៀតថា ការព្រួយបារម្ភជាច្រើន ដែលសហមេធាវីការពារក្តីបានលើកឡើងអំពីករណីដែលសហចៅក្រមស៊ើបអង្កេត មិនគោរពគោលការណ៍សន្និដ្ឋានជាមុននៃភាពគ្មានទោស ត្រូវបានដោះស្រាយ តាមរយៈការវិភាគដែលអង្គជំនុំជម្រះនេះ បានអនុវត្ត*"។

នៅខណៈពេលដែល សចស ចេញដីកាសម្រេចបន្តថិរវេលាឃុំខ្លួននោះទេ[18]។ ដូចដែលបានលើកឡើងនៅក្នុងសេចក្តីសម្រេច លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ដែលចេញបន្តគ្នានោះ អបជ បានកត់សម្គាល់ឃើញថា អបជ ពិចារណាអំពីសំណុំរឿងរបស់ សចស ទាំងមូលដែលមានមកទល់ថ្ងៃសវនាការ[19] រួមទាំងធាតុផ្សំថ្មីណាមួយ ឬចំណែកណាមួយនៃភស្តុតាងដែលបានដាក់ចាប់តាំងពីមានបណ្តឹងឧទ្ធរណ៍មក។ សហព្រះរាជអាជ្ញាសន្និដ្ឋានថា ហេតុនេះ អបជ ត្រូវធ្វើការពិចារណាមិនត្រឹមតែលើភស្តុតាងថ្មី ដែលបានដាក់ចាប់តាំងពីមានដីកា និងបណ្តឹងឧទ្ធរណ៍ មកទល់នឹងថ្ងៃសវនាការនោះទេ ថែមទាំងត្រូវពិចារណាផងដែរលើអង្គហេតុ ដែលជនត្រូវចោទត្រូវបានជូនដំណឹងអំពីការចោទប្រកាន់បន្ថែម កាលពីថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៩ ។

## *ការអនុវត្តឆន្ទានុសិទ្ធិក្នុងការពិចារណាអំពីការឃុំខ្លួន*

9. សិទ្ធិអំណាចតុលាការអាចអនុវត្តឆន្ទានុសិទ្ធិក្នុងការកំណត់សម្រេចថាតើ ការឃុំខ្លួនបណ្តោះអាសន្នគឺជាវិធានការដ៏ចាំបាច់ ឬការបន្តថិរវេលាឃុំខ្លួនត្រូវបានធានាអះអាងដែរឬទេ។ ឆន្ទានុសិទ្ធិនេះជាធម្មតា ត្រូវបានអនុវត្តដោយធ្វើការពិចារណាលើឯកសារនៅក្នុងសំណុំរឿង និងអង្គហេតុនៃរឿងក្តីដែលពាក់ព័ន្ធទាំងអស់ រួមទាំងស្ថានទម្ងន់នៃការចោទប្រកាន់ ភាពសមហេតុ សមផលនៃភស្តុតាង បុគ្គលិកលក្ខណៈនិងឥរិយាបថពីអតីតកាលនិងបច្ចុប្បន្នកាលរបស់ជនត្រូវចោទ ផលប្រយោជន៍របស់សាក្សី និងផលប្រយោជន៍នៃភាពយុត្តិធម៌ទាំងមូល[20]។ ចំណុចនេះ គឺអនុលោមតាមមេរៀន

---

[18] អ.ប.ជ ពិនិត្យឡើងវិញលើដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នដោយ "ធ្វើការត្រួតពិនិត្យលើ៖ ក. នីតិវិធីរបស់សហចៅក្រមស៊ើបអង្កេត មុនពេលចេញដីកានេះ។ ខ. ភាពគ្រប់គ្រាន់នៃអង្គហេតុ ក្នុងការចេញដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ស្របតាមវិធាន៦៣(៣) នៃវិធានផ្ទៃក្នុង។ គ. ថាតើកាលៈទេសៈ ដែលដីកាបានយកមកធ្វើជាសម្អាង នៅមានអត្ថិភាពនាពេលបច្ចុប្បន្ន ដែរឬទេ។ និង ឃ. ការអនុវត្តឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេត ដោយគោរពតាមវិធាន ៦៣(៣) នៃវិធានផ្ទៃក្នុង", *ក្នុង* សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទ អៀង ធីរិទ្ធ, ឯកសារ C20/I/26, ERN 00201588-604 (ភាសាអង់គ្លេស), ត្រង់ ERN 00201591, កថាខណ្ឌ១៥។ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទ នួន ជា, ចុះថ្ងៃទី២០ ខែមីនា ២០០៨, ឯកសារ C11/54, ERN 00172907-34 (ភាសាអង់គ្លេស) ត្រង់ ERN 00172909, កថាខណ្ឌ៩។

[19] ឧទាហរណ៍, សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទ អៀង ធីរិទ្ធ, ឯកសារ C20/I/26, ERN 00201588-604 (ភាសាអង់គ្លេស) at ERN 00201592, កថាខណ្ឌ២០។

[20] រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Ljube Baskoski និង Johan Tarculovski, សាលដីកាលើបណ្តឹងឧទ្ធរណ៍បន្ទាន់បង្ខំរបស់ Johan Tarculovski ស្តីពីការដោះលែងបណ្តោះអាសន្ន, រឿងក្តីលេខ IT-04-82-AR65.4, អង្គជំនុំជម្រះតុលាការកំពូល ICTY, ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៧, កថាខណ្ឌ៥។

ដែលត្រូវបានទទួលស្គាល់នៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិនានា ដែលត្រូវបានអនុម័តដោយតុលាការនេះផងដែរ[21]។

## *ភារកិច្ចក្នុងការផ្ដល់មូលហេតុក្នុងការចេញដីកាឃុំខ្លួន*

10. វិធាន ៦៣(៧) កំណត់លក្ខខណ្ឌឲ្យសហចៅក្រមស៊ើបអង្កេត "កំណត់មូលហេតុនានា" សម្រាប់ការបន្តថិរវេលានៃការឃុំខ្លួន។ មូលហេតុទាំងអស់នេះត្រូវផ្តល់ឲ្យបន្ទាប់ពីបានពិចារណាលើសំណុំរឿង និងការជំទាស់នានារបស់អ្នកជាប់ឃុំឃាំង[22]។ បន្ទាប់ពីបានរៀបរាប់អំពីយុត្តិសាស្ត្រអន្តរជាតិដែលបានព្រមព្រៀង អបជ បានយល់ឃើញថា រាល់សេចក្តីសម្រេចទាំងអស់របស់អង្គភាពតុលាការ រួមទាំង សចស ត្រូវផ្តល់ហេតុផលដើម្បីបំពេញបទដ្ឋានអន្តរជាតិ[23]។

11. អបជ បានកំណត់សម្រេចថា កាតព្វកិច្ចក្នុងការលើកឡើងនូវមូលហេតុ គ្រាន់តែកំណត់លក្ខខណ្ឌឲ្យ សចស កំណត់មូលដ្ឋានផ្លូវច្បាប់នានា និងអង្គហេតុនានាដែលបានយកមកពិចារណាមុនពេលចេញសេចក្តីសម្រេចតែប៉ុណ្ណោះ។ សចស អាចរួចផុតពីកាតព្វកិច្ចនេះ "តាមរយៈការយោងលើសំណុំរឿងក្នុងកាលៈទេសៈទូទៅ និងកាលៈទេសៈផ្សេងទៀត" នៅពេលដែល សចស មិនមានកាតព្វកិច្ចផ្តល់ការយល់ឃើញរបស់ខ្លួនលើកត្តាទាំងអស់នោះឡើយ[24]។ ដីកាសម្រេចបន្តថិរវេលាឃុំខ្លួន បានផ្តល់មូលហេតុគ្រប់គ្រាន់ និងពេញលេញហើយ។

---

[21] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទ ឌុច, កថាខណ្ឌ២៧។

[22] អនុលោមតាមវិធាន ៦៣(៧) នៃវិធានផ្ទៃក្នុង, មុនពេលបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ការបន្តថិរវេលាដំណើរការនីតិវិធីកើតឡើងតែរវាងសហចៅក្រមស៊ើបអង្កេត និង ជនត្រូវចោទ តែប៉ុណ្ណោះ សហចៅក្រមស៊ើបអង្កេតស្តាប់តែការជំទាស់របស់ជនត្រូវចោទតែប៉ុណ្ណោះ។ មិនមានភាគីផ្សេងត្រូវបានស្តាប់ ឬ ត្រូវបានជាប់ទាក់ទងក្នុងនីតិវិធីនេះទេ។ ដូច្នេះនីតិវិធីនៃការបន្តថិរវេលាក្រោមវិធាន៦៣(៧) ខុសពីនីតិវិធីនៃការឃុំខ្លួនបឋមក្រោមវិធាន៦៣(៣) ដែលរួមបញ្ចូលទាំងសវនាការតទល់គ្នា នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត។

[23] *រឿងក្តី នួន ជា*, សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា ប្រឆាំងនឹងដីកាបដិសេធពាក្យសុំមោឃភាព ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៨, សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស (អ.ប.ជ០៦), ឯកសារ **D55/I/8**, ERN 001219322-33 (ភាសាអង់គ្លេស), កថាខណ្ឌ២១។

[24] *រឿងក្តី អៀង សារី,* សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទ អៀង សារី, សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស (អ.ប.ជ០៣) ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៨, ឯកសារ **C22/I/74**, ERN 00232976-004 (ENG), កថាខណ្ឌ ៦៤-៦៦ (*បន្ទាប់ពីនេះ* សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទ អៀង សារី)។ សូមមើលផងដែរ រឿងក្តីតុលាការ ICTY៖ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Popovic,* សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍បន្ទាន់បង្ហិរបស់មេធាវីការពារក្តី នៃសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង បដិសេធការដោះលែង Ljubomir Borovcanin បណ្តោះអាសន្ន, រឿងក្តីលេខ IT-05-88-AR65.2, អង្គជំនុំជម្រះតុលាការកំពូល, ចុះថ្ងៃទី១ ខែមីនា ឆ្នាំ២០០៧, កថាខណ្ឌ១៣។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Haradinaj,* សាលដីកា

## IV. ឧបនីករណ៍

*ការពន្យារចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន និង ការពន្យាររយៈពេលមិនសមស្រប*

12. វិធាន ៦៣(៦) និង (៧) នៃវិធានផ្ទៃក្នុង អនុញ្ញាតដោយស្វ័យប្រវត្តិឱ្យមានការពិនិត្យឡើងវិញយ៉ាងទៀងពេលកំណត់លើការឃុំខ្លួនជនត្រូវចោទ។ បទប្បញ្ញត្តិបែបនេះមិនឃើញមានចែងនៅក្នុងលិខិតបទដ្ឋានចំបងៗរបស់សាលាក្តីព្រហ្មទណ្ឌអន្តរជាតិ សម្រាប់អតីតប្រទេសយូហ្គោស្លាវី("ICTY") សាលាក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ្វ៉ាន់ដា("ICTR") និងតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន("SCSL")ទេ។ ទោះបីជាយ៉ាងនេះក្តី សាលាក្តីទាំងនេះនៅតែលើកឡើងថា ដើម្បីឱ្យពាក្យសុំឱ្យនៅក្រៅឃុំដែលបានដាក់សារជាថ្មីនោះទទួលយកបាន ជនត្រូវចោទត្រូវតែបង្ហាញថាមាន"ការផ្លាស់ប្តូរកាលៈទេសៈជាក់ស្តែងណាមួយ"យ៉ាងពិតប្រាកដ[25]។

13. មិនខុសពីវិធានផ្ទៃក្នុងរបស់សាលាក្តីនេះ វិធាន ១១៨ នៃវិធានស្តីពីនីតិវិធី និងភស្តុតាង របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ("ICC") ចែងថា អង្គបុរេជំនុំជម្រះត្រូវពិនិត្យឡើងវិញលើការឃុំខ្លួនជនត្រូវចោទនៅមុនពេលជំនុំជម្រះយ៉ាងហោចណាស់ក្នុងរយៈពេល១២០ ថ្ងៃម្តង។ អង្គបុរេជំនុំជម្រះរបស់ ICC មាន"កាតព្វកិច្ចពិសេស និងឯករាជ្យមួយ [...] ក្នុងការធ្វើយ៉ាងណាកុំឱ្យមានការឃុំខ្លួនជនណាម្នាក់ក្នុងរយៈពេលមិនសមស្របនៅមុនពេលជំនុំជម្រះ"[26]។ អង្គបុរេជំនុំជម្រះអាចកែប្រែសេចក្តីសម្រេចរបស់ខ្លួនលើការឃុំខ្លួន "ប្រសិនបើខ្លួនជឿថា ការផ្លាស់ប្តូរនៃកាលៈទេសៈនោះវាទាមទារឱ្យធ្វើដូច្នេះមែន"[27]។ នៅ ICC "ស្ថាប័នអយ្យការមានបន្ទុកក្នុងការបង្ហាញភស្តុតាងថា លក្ខខណ្ឌ[...]នៃការឃុំខ្លួននៅមុនពេលជំនុំជម្រះពិតជានៅមានអត្ថិភាព"[28]។

---

សម្រេចលើពាក្យសុំដោះលែងបណ្តោះអាសន្នរបស់ Lahi Brahimaj រឿងក្តីលេខ IT-04-84-PT, អង្គជំនុំជម្រះសាលាដំបូង ICTY, ចុះថ្ងៃទី៣ ខែឧសភា ឆ្នាំ២០០៦, កថាខណ្ឌ១៦។

[25] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Boskoski និង Tarculovski,* រឿងក្តីលេខ IT-04-82-PT, សេចក្តីសម្រេចទាក់ទងនឹងពាក្យសុំថ្មីសម្រាប់ការដោះលែង Johan Tarculovski បណ្តោះអាសន្ន, ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៧, កថាខណ្ឌ៩។

[26] *ស្ថានភាពនៅក្នុងសាធារណរដ្ឋប្រជាធិបតេយ្យ កុងហ្គោ, ក្នុងរឿងក្តីរដ្ឋអាជ្ញា តទល់នឹង Germaine Katanga និង Mathieu Ngudjolo Chui,* សេចក្តីសម្រេចទាក់ទងនឹងការសង្កេតលើការពិនិត្យឡើងវិញនៃការឃុំខ្លួនមុនពេលកាត់ក្តី នៃ Germaine Katanga, រឿងក្តីលេខ ICC-01/04-01/07, អង្គបុរេជំនុំជម្រះ, ចុះថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០០៨, ទំព័រ៤។

[27] *ស្ថានភាពនៅក្នុងសាធារណរដ្ឋប្រជាធិបតេយ្យ កុងហ្គោ, ក្នុងរឿងក្តីរដ្ឋអាជ្ញា តទល់នឹង Germaine Katanga និង Mathieu Ngudjolo Chui,* ការពិនិត្យឡើងវិញលើលក្ខខណ្ឌនៃការឃុំខ្លួនមុនពេលកាត់ក្តី នៃ Germaine Katanga, រឿងក្តីលេខ ICC-01/04-01/07, អង្គបុរេជំនុំជម្រះ, ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៨, ទំព័រ៦។

[28] *ស្ថានភាពនៅក្នុងសាធារណរដ្ឋប្រជាធិបតេយ្យ កុងហ្គោ, ក្នុងរឿងក្តីរដ្ឋអាជ្ញា តទល់នឹង Germaine Katanga និង Mathieu Ngudjolo Chui,* សេចក្តីសម្រេចទាក់ទងនឹងការសង្កេតលើការពិនិត្យឡើងវិញនៃការខ្លួនមុនពេលកាត់ក្តីនៃ Germaine Katanga, រឿងក្តីលេខ ICC-01/04-01/07, អង្គបុរេជំនុំជម្រះ, ចុះថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០០៨, ទំព័រ៤។

14. នៅក្នុងសាលាក្តីនេះ វិធាន ៦៣(៧)នៃវិធានផ្ទៃក្នុងចែងថា សហចៅក្រមស៊ើបអង្កេតមិនចាំបាច់ធ្វើការស្តាប់សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ឬ ភាគីណាមួយផ្សេងទៀតក្រៅតែពីជនត្រូវចោទឡើយ នៅពេលធ្វើការសម្រេចបន្តចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន។ សហចៅក្រមស៊ើបអង្កេតគ្រាន់តែអនុញ្ញាតឱ្យជនត្រូវចោទដាក់នូវការជំទាស់តវ៉ារបស់ខ្លួនតែប៉ុណ្ណោះ។ អត្ថិភាពនៃការពិនិត្យឡើងវិញដោយស្វ័យប្រវត្តិលើការបន្តចិរវេលានៃការឃុំខ្លួន ផ្តល់ឱកាសដល់ជនជាប់ឃុំដាក់ជូននូវជំហររបស់ខ្លួន ហើយប្រសិនបើចាំបាច់ វាបើកឱ្យជននេះអនុវត្តសិទ្ធិប្តឹងឧទ្ធរណ៍របស់ខ្លួនចំពោះសេចក្តីសម្រេចដែលមានសំអាងហេតុ[29]។ វាជាកាតព្វកិច្ចរបស់ភាគីដែលប្តឹងឧទ្ធរណ៍ដែលត្រូវបង្ហាញអំពីការផ្លាស់ប្តូរកាលៈទេសៈជាក់ស្តែង ពីព្រោះការបន្តចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នលើកដំបូងនោះត្រូវបានតម្កល់ទុកជាបានការដោយ អបជ។ ផ្ទុយពីអ្វីដែលក្រុមមេធាវីការពារក្តីបានលើកឡើង[30] វាពុំមែនជាគោលនយោបាយរបស់សហចៅក្រមស៊ើបអង្កេតក្នុង "ការបន្តចិរវេលានៃឃុំខ្លួនមុនពេលជំនុំជម្រះដោយស្វ័យប្រវត្តិ"នោះឡើយ។ ការពិនិត្យឡើងវិញដោយស្វ័យប្រវត្តិយ៉ាងទៀងពេលកំណត់លើការឃុំខ្លួនជនត្រូវចោទជាបណ្តោះអាសន្ននោះ ជាយន្តការធានាដល់សិទ្ធិរបស់ជនត្រូវចោទ។ សហចៅក្រមស៊ើបអង្កេតមានកាតព្វកិច្ចពិតប្រាកដក្នុងការវាយតម្លៃឡើងវិញលើលក្ខណៈវិនិច្ឆ័យដើម្បីបន្តចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន នៅមុនពេលផុតរយៈពេលនៃការបន្តចិរវេលានៃការឃុំខ្លួននេះ ដោយត្រូវពិចារណាលើសេចក្តីសង្កេតរបស់ក្រុមមេធាវីការពារក្តី។ ម្យ៉ាងវិញទៀត វិធាន ៦៤ នៃវិធានផ្ទៃក្នុងចែងថា សហចៅក្រមស៊ើបអង្កេតតាមការផ្តួចផ្តើមរបស់ខ្លួន ត្រូវចេញដីកាដោះលែងជនត្រូវចោទជាបណ្តោះអាសន្ន ក្នុងករណីដែលលក្ខខណ្ឌស្តីពីការឃុំខ្លួនបណ្តោះអាសន្ន ដូចមានចែងនៅក្នុងវិធាន ៦៣ លែងបានបំពេញទៀតហើយនោះ។ ចំនុចនេះបង្កប់ន័យថា លក្ខខណ្ឌទាំងនោះត្រូវយកមកវាយតម្លៃឡើងវិញជាអចិន្ត្រៃយ៍។

15. ក្រៅពីការផុតនៃរយៈពេលកំណត់ ភាគីដែលប្តឹងឧទ្ធរណ៍មិនបានបង្ហាញនូវការផ្លាស់ប្តូរកាលៈទេសៈជាក់ស្តែង ដែលជាលក្ខខណ្ឌចាំបាច់នាំឱ្យមានការពិចារណាលើការឃុំខ្លួនរបស់ជនត្រូវចោទឡើងវិញនោះទេ។ ទោះបីជាសាលាក្តីអន្តរជាតិទាំងឡាយបានចាត់ទុកថា រយៈពេលកំណត់នៃការឃុំខ្លួន

---

[29] វិធាន ៦៣(៧) នៃវិធានផ្ទៃក្នុង។

[30] បណ្តឹងឧទ្ធរណ៍, កថាខណ្ឌ១២។

ជាកត្តាពាក់ព័ន្ធមួយនៅក្នុងការសម្រេចអំពីនីត្យានុកូលភាពនៃការឃុំខ្លួន[31] ក្រុមមេធាវីការពារក្ដីមិនបានបង្ហាញ ថាតើការឃុំខ្លួនរយៈពេលពីរឆ្នាំនេះបានប៉ះពាល់ដល់ករណីរបស់ភាគីដែលប្ដឹងឧទ្ធរណ៍នេះដោយរបៀបណា ដែលជាហេតុនាំឱ្យរាំងដល់ការជំនុំជម្រះមួយដ៏យុត្តិធម៌ និង/ឬអាចនាំឱ្យបង្ហាញថា ការប៉ះពាល់នេះអាចធ្វើឱ្យមានយុត្តិកម្មក្នុងការពិចារណាលើការឃុំខ្លួនបណ្ដោះអាសន្ននេះឡើងវិញនោះទេ។

16. វិធានផ្ទៃក្នុងចែងអំពីរយៈពេលកំណត់នៃការឃុំខ្លួនបណ្ដោះអាសន្ន ដូច អបជ បានរំលឹកឡើងវិញនៅក្នុងថ្ងៃទី១១ ខែឧសភា ឆ្នាំ២០០៩។ អបជ បានលើកឡើងថា វិធាន ៦៣(៦) និង (៧) នៃវិធានផ្ទៃក្នុងចែងថា "ការពន្យារពេលមិនត្រូវលើសពីពីរដងបានឡើយ"។ អបជ បានលើកឡើងទៀតថា ចំពោះការយកចិត្តទុកដាក់ឱ្យបានត្រឹមត្រូវនោះ វិធាន ២១(៤)នៃវិធានផ្ទៃក្នុងចែងថា "ការសម្រេចសេចក្ដីលើការចោទប្រកាន់ចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ ត្រូវធ្វើការជំនុំជម្រះក្នុងរយៈពេលសមស្របមួយ"[32]។ បន្ទាប់ពីពិនិត្យមើលឡើងវិញលើយុត្តិសាស្ត្រទាក់ទងនឹងចំនុចនេះ អបជ បានលើកឡើងថា "ភាពសមហេតុផលនៃរយៈពេលឃុំខ្លួន និងការយកចិត្តទុកដាក់របស់សហចៅក្រមស៊ើបអង្កេតក្នុងការអនុវត្តការស៊ើបអង្កេតគឺជាកត្តាដែលត្រូវយកមកពិចារណា នៅពេលអនុវត្តអំណាចឆន្ទានុសិទ្ធិក្នុងការសម្រេចបន្តថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន"[33]។ អបជ បានសន្និដ្ឋានថា "សហចៅក្រមស៊ើបអង្កេតបានអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនយ៉ាងត្រឹមត្រូវ នៅក្នុងការសម្រេចបន្តថិរវេលានៃកាឃុំខ្លួន ពីព្រោះថិរវេលានៃការឃុំខ្លួនមានលក្ខណៈសមហេតុផល ដោយគិតគូរអំពីទំហំនៃឧក្រិដ្ឋកម្មដែលកំពុងត្រូវបានស៊ើបអង្កេត និងសកម្មភាពដែលសហចៅក្រមស៊ើប

---

[31] *រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង Tihomir Blaskic,* ដីកាបដិសេធពាក្យសុំដោះលែងបណ្ដោះអាសន្ន, រឿងក្ដីលេខ IT-94-14- អង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៦៖ តុលាការ ICTY បានបង្កើតក្នុងសេចក្ដីសម្រេចនោះថា ដើម្បីធ្វើឲ្យមានលក្ខណៈសមស្របនៃរយៈពេលនៃការឃុំខ្លួនបណ្ដោះអាសន្ន វាចាំបាច់ត្រូវវាយតម្លៃកាលៈទេសៈនៃករណីនីមួយៗក្នុងលក្ខណៈវិនិច្ឆ័យដូចខាងក្រោម៖ (ក) រយៈពេលដ៏មានប្រសិទ្ធភាពនៃការឃុំខ្លួន។ (ខ) រយៈពេលនៃការឃុំខ្លួនទាក់ទងនឹងប្រភេទនៃឧក្រិដ្ឋកម្ម។ (គ) ផលវិបាករូបវន្ត និង ចិត្តសាស្ត្រ នៃការឃុំខ្លួនអ្នកជាប់ឃុំ។ (ឃ) ភាពស្មុគស្មាញនៃរឿងក្ដីនិង ការស៊ើបអង្កេត។ (ង) ការប្រព្រឹត្តិនៃដំណើរការនីតិវិធីរឿងក្ដីទាំងមូល។ ស្ថានភាពនៅក្នុងសាធារណរដ្ឋប្រជាធិបតេយ្យ កុងហ្គោ, ក្នុងរឿងក្ដីរដ្ឋអាជ្ញាតទល់នឹង Germain Katanga និង Mathieu Ngudjolo Chui, ការពិនិត្យឡើងវិញនៃសេចក្ដីសម្រេចលើពាក្យសុំសម្រាប់ការដោះលែង Mathieu Ngudjolo Chui បណ្ដោះអាសន្ន, រឿងក្ដីលេខ 01/04-01/07, អង្គបុរជំនុំជម្រះនៃតុលាការ ICC, ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨, ទំព័រ១២។

[32] សាលដីកាលើបណ្ដឹងឧទ្ធរណ៍អំពីការបន្តថិរវេលាលើកទីមួយ, កថាខណ្ឌ ៥៥។

[33] សាលដីកាលើបណ្ដឹងឧទ្ធរណ៍អំពីការបន្តថិរវេលាលើកទីមួយ, កថាខណ្ឌ៦១។

អង្កេតកំពុងអនុវត្ត”[34]។ នៅពេលនេះ ចំនុចនេះកាន់តែសំខាន់ទៅទៀតនៅពេលយើងពិចារណាលើការចោទប្រកាន់បន្ថែមកាលពីថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៩ ទៅលើដើមបណ្តឹងឧទ្ធរណ៍ ពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ការរំលោភបំពានធ្ងន់ធ្ងរនៃអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ និងឧក្រិដ្ឋកម្មតាមច្បាប់ជាតិ។ ក្រុមមេធាវីការពារក្តីមិនបានផ្តល់ជាភស្តុតាងគាំទ្រលើភាពអាចអនុវត្តទៅបាននូវបទដ្ឋាន “ការយកចិត្តទុកដាក់ពិសេស”របស់តុលាការអ៊ឺរ៉ុបផ្នែកសិទ្ធិមនុស្ស (ECHR) ហើយមិនបានផ្តល់ជាភស្តុតាងថ្មីណាមួយចាប់តាំងពីថ្ងៃទី១១ ខែឧសភា ឆ្នាំ២០០៩ ដែលអាចឱ្យ អបជ ជឿថា រយៈពេលនៃការឃុំខ្លួននេះមានភាពមិនសមស្រប។

17. ដូចដែលបានលើកឡើងនៅក្នុងកថាខណ្ឌ ២២ ខាងក្រោម សហចៅក្រមស៊ើបអង្កេតបានបន្តការស៊ើបអង្កេតទៅមុខរបស់ខ្លួនដោយការរីកចម្រើនយ៉ាងខ្លាំងក្លា។ ក្រោយពិចារណាលើកាលៈទេសៈនៃរឿងក្តី និងយុត្តិសាស្ត្រអន្តរជាតិ រយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្នលើភាគីដែលប្តឹងឧទ្ធរណ៍មានភាពសមហេតុសមផល អនុលោមតាមមាត្រា ៩(៣) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR)។ ជនត្រូវចោទត្រូវបានជាប់ឃុំបណ្តោះអាសន្នក្នុងរយៈពេលសមស្រប ប្រសិនបើយើងពិចារណាលើភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មទាំងឡាយ ដែលបានចោទប្រកាន់ ភាពស្មុគស្មាញនៃរឿងក្តី ដំណើរការនៃកិច្ចដំណើរការនីតិវិធី និងវិសាលភាពនៃការការស៊ើបអង្កេតដែលកំពុងបន្តរបស់សហចៅក្រមស៊ើបអង្កេត។ យន្តការធានាដូចមានចែងនៅក្នុងវិធានផ្ទៃក្នុងដែលបានកម្រិតរយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្ន ហើយដែលបានចែងអំពីការពិនិត្យឡើងវិញលើការឃុំខ្លួនបណ្តោះអាសន្ន បានបន្ថយនូវការព្រួយបារម្ភថា រយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្ននឹងនាំឱ្យមានភាពមិនសមស្រប។ ដោយសារហេតុផលទាំងនេះហើយ សហព្រះរាជអាជ្ញាសូមស្នើសុំឱ្យ អបជ ច្រានចោលបណ្តឹងឧទ្ធរណ៍របស់ក្រុមមេធាវីការពារក្តីចាត់ទុកជាឥតបានការ។

***វិធាន ៦៣(៣) លក្ខខណ្ឌទាំងឡាយដែលតម្រូវឱ្យមានការឃុំខ្លួនបណ្តោះអាសន្ន***

18. លក្ខខណ្ឌចំនួនពីរដូចមានចែងនៅក្នុងវិធាន ៦៣(៣) នៃវិធានផ្ទៃក្នុងនៅតែបានបំពេញ ហើយផ្តល់យុត្តិកម្មចំពោះការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ក្នុងរយៈពេលអតិបរមាមួយឆ្នាំទៀត។

***ក. មូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់ - វិធាន ៦៣(៣)(ក)***

---

[34] សាលដីកាលើបណ្តឹងឧទ្ធរណ៍អំពីការបន្តថិរវេលាលើកទីមួយ, កថាខណ្ឌ ៦៧។

00424668



19. ក្នុងពេលបច្ចុប្បន្ននេះ សំណុំរឿងនេះនៅមានភស្តុតាងដែលអាចឱ្យអ្នកសង្កេតការណ៍មិនលម្អៀងជឿថា នៅក្នុងដំណាក់កាលនេះ ភាគីដែលប្តឹងឧទ្ធរណ៍អាចធ្លាប់បានប្រព្រឹត្តឧក្រិដ្ឋកម្មទាំងឡាយដែលគេកំពុងធ្វើការស៊ើបអង្កេតលើខ្លួន។

20. នៅក្នុងបណ្តឹងឧទ្ធរណ៍នេះ ក្រុមមេធាវីការពារក្តីមិនបានដាក់ជូននូវទឡ្ហីករណ៍ណាមួយដែលពាក់ព័ន្ធ ផ្អែកតាមវិធាន ៦៣(៣)(ក)ឡើយ។ ជាការពិត ក្រុមមេធាវីការពារក្តីបានធ្វើការតវ៉ាទាំងភ័ន្តច្រឡំអំពីអត្ថិភាពនៃមូលហេតុដែលត្រូវបានរកឃើញនិងជឿជាក់យ៉ាងច្បាស់ ដោយខ្លួនបានលើកឡើងថា សហចៅក្រមស៊ើបអង្កេតខកខានមិនបានពិចារណាលើភស្តុតាងដោះបន្ទុក ហើយមិនបានថ្លឹងថ្លែងគ្រប់គ្រាន់លើភស្តុតាងទាំងនេះ។ ក្រុមមេធាវីការពារក្តីបានបន្តលើកឡើងទៀតថា សហចៅក្រមស៊ើបអង្កេត"មិនបានបំពេញកិច្ចដោយអនាគតិ ហើយមិនបានធ្វើការវាយតម្លៃលើភស្តុតាងឱ្យបានសមស្រប និងត្រឹមត្រូវ"។ ក្រុមមេធាវីបានផ្តល់មូលដ្ឋានគាំទ្រចំពោះការអះអាងបែបនេះ ដោយយោងទៅរកសក្ខីកម្មរបស់សាក្សីមួយរូប **(ត្រូវបានលុបចេញ)** និងសម្រង់នៃការសម្ភាសលើលោក **កាំង ហ្គេកអ៊ាវ** ហៅ **"ឌុច"**។

21. អនុលោមតាមវិធាន ៦៣(៣)(ក) តួនាទីរបស់សហចៅក្រមស៊ើបអង្កេតគឺត្រូវវាយតម្លៃលើគ្រប់ភស្តុតាងទាំងអស់ ដែលខ្លួនប្រមូលបានមកទល់ពេលបច្ចុប្បន្ន ដើម្បីសម្រេចថាតើមានមូលហេតុដែលត្រូវបានរកឃើញនិងជឿជាក់យ៉ាងច្បាស់ថា ជនត្រូវចោទបានប្រព្រឹត្តឧក្រិដ្ឋកម្មដែរឬទេ។ ភស្តុតាងទាំងឡាយដែលសហចៅក្រមស៊ើបអង្កេតប្រមូលបាន បង្ហាញយ៉ាងច្បាស់អំពីករណីនេះ។ ទឡ្ហីករណ៍របស់ភាគីដែលប្តឹងឧទ្ធរណ៍ស្តីពីអនាគតិរបស់សហចៅក្រមស៊ើបអង្កេត មិនអាចទទួលយកបាននៅក្នុងបណ្តឹងឧទ្ធរណ៍មួយនេះ។ វិធានផ្ទៃក្នុង ផ្តល់លទ្ធភាពឱ្យជនត្រូវចោទតវ៉ាលើករណីដែលស្ថាប័នតុលាការនៅក្នុង អ.វ.ត.ក មិនមានអនាគតិ ដោយអនុញ្ញាតឱ្យដាក់ពាក្យសុំប្តឹងជំទាស់ អនុលោមតាមវិធាន ៣៤ នៃវិធានផ្ទៃក្នុង។ **(ត្រូវបានលុបចេញ)**

ម្យ៉ាងវិញទៀត វាក៏មានការគូសបញ្ជាក់ផងដែរថា នៅក្នុងដីកាបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នលើកទី២ សហចៅក្រមស៊ើបអង្កេតបានយោងយ៉ាងច្បាស់លើចំណុចចំនួនពីរនៅក្នុងសក្ខីកម្មរបស់សាក្សី **(បានលុបចេញ)** (កំណត់សម្គាល់ជើងទំព័រ ៣៥-៣៦) ដោយនៅក្នុងកំណត់សម្គាល់នោះមានភស្តុតាងដោះបន្ទុក ហើយថែមទាំងបានដកស្រង់ផ្នែកដែលជាប់ទាក់ទងផងដែរនៅក្នុងលេខយោង ៣៥។ គេមិនអាចតវ៉ាថា សហចៅក្រមស៊ើបអង្កេតមិនបានថ្លឹងថ្លែងគ្រប់គ្រាន់លើសក្ខីកម្មនេះឡើយ។ ចំពោះ

សេចក្តីថ្លែងការណ៍របស់ ឌុច (ត្រូវបានលុបចេញ) គេគួរពិចារណារួមគ្នាលើសេចក្តីថ្លែងការណ៍មួយចំនួនផ្សេងទៀតក្នុងបរិបទទូលាយជាងនេះ ដែលនៅក្នុងនោះ ឌុច (បានលុបចេញ)

[35]។

22. សហព្រះរាជអាជ្ញាចាត់ទុកថាមានភាពចាំបាច់ ក្នុងការលើកឡើងអំពីភស្តុតាងដាក់បន្ទុកឱ្យបានច្រើន ដែលសហចៅក្រមស៊ើបអង្កេតបានប្រមែលប្រមូលចាប់តាំងពីថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៨ មកម្ល៉េះ។ ហេតុដូច្នេះហើយ ទើបសហព្រះរាជអាជ្ញាបានបញ្ចូលចំនុចនេះដោយយោងលើការលើកឡើងទាំងឡាយដូចមានរៀបរាប់នៅក្នុងកថាខណ្ឌទី ៣៩ ដល់ កថាខណ្ឌទី ៤៤ នៅក្នុង "សេចក្តីសន្និដ្ឋានតបរបស់ខ្លួន ចំពោះបណ្តឹងឧទ្ធរណ៍របស់ក្រុមមេធាវីការពារក្តីទៅនឹងដីកាឃុំខ្លួនបណ្តោះអាសន្នចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៨"។ សេចក្តីសន្និដ្ឋានតបនេះចុះថ្ងៃទី៩ ខែមករា ឆ្នាំ២០០៩[36]។ ពាក់ព័ន្ធនឹងភស្តុតាងដែលប្រមូលបានតាំងពីអម្តុងពេលសវនាការរបស់ អបជ កាលពីថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០០៩ សហព្រះរាជអាជ្ញាបានកត់សម្គាល់ជាដំបូងឃើញថា នៅក្នុងកថាខណ្ឌទី ១៤ និង ៣០ នៃដីកាបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន សហចៅក្រមស៊ើបអង្កេត *តាមការផ្តួចផ្តើមរបស់ខ្លួន* ឬ តាមសំណើរបស់ភាគី បានផ្តល់នូវព័ត៌មានពិស្តារយ៉ាងគ្រប់គ្រាន់លើឯកសារភស្តុតាងបន្ថែមទៀត ដែលមាននៅក្នុងសំណុំរឿង ដោយក្នុងនោះយ៉ាងហោចណាស់មានសក្ខីកម្មចំនួន ២១ របស់សាក្សីថ្មីៗទាំងឡាយ ដែលមានភាពជាប់ពាក់ព័ន្ធដោយផ្ទាល់។ សហព្រះរាជអាជ្ញាក៏បានលើកឡើងកាលពីថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៩ ក្នុងរយៈពេលជិតមួយខែមុនពេលបណ្តឹងឧទ្ធរណ៍ត្រូវបានដាក់ផងដែរថា ភាគីត្រូវបានជូនដំណឹងអំពីការបន្ថែមកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីចំនួន ២៤ ដែលមានលេខយោង D231/3 - D231/26។ ក្នុងចំណោមសក្ខីកម្មទាំងនេះ ការស្តាប់ចម្លើយដែលមានការពាក់ព័ន្ធជាងគេមានដូចជាចម្លើយរបស់ (ត្រូវបានលុបចេញ)

---

[35] ការយោងត្រូវបានធ្វើក្នុងផ្នែកនេះ ទាក់ទងនឹងអំណះអំណាងដែលបានលើកឡើងក្នុងកថាខណ្ឌ៤២ និង ៤៣ នៃការឆ្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់លោកស្រី អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៨, ចុះថ្ងៃទី៩ ខែមករា ឆ្នាំ២០០៩, ឯកសារ C20/5/7, ERN 00270423-49 (ភាសាអង់គ្លេស) ត្រង់ 00270443-44 ។

[36] *រឿងក្តី អៀង ធីរិទ្ធ,* ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់លោកស្រី អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៨, ចុះថ្ងៃទី៩ ខែមករា ឆ្នាំ២០០៩, ឯកសារ C20/5/7, ERN 00270423-49 (ភាសាអង់គ្លេស)។

[37]។ អ្នកទាំងនេះបានផ្តល់ព័ត៌មានចំបងៗពាក់ព័ន្ធនឹងតួនាទីរបស់ជនត្រូវចោទនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ និង ការចូលរួមរបស់ជននេះនៅក្នុងឧក្រិដ្ឋកម្មទាំងឡាយដែលចោទប្រកាន់លើខ្លួន។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីដែលមានការពាក់ព័ន្ធ ជាងនេះទៀតនោះត្រូវបានបញ្ចូលទៅក្នុងសំណុំរឿង[38] ដើម្បីធ្វើការវិភាគបន្ថែម ។

23. ដូច្នេះ ផ្អែកតាមហេតុផលខាងលើ សហព្រះរាជអាជ្ញាស្នើសុំឱ្យ អបជ ច្រានចោលមូលដ្ឋានទាំងនេះដែលបានលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍ ហើយតម្កល់ទុកនូវលក្ខខណ្ឌនៃការឃុំខ្លួនដូចមានចែងនៅក្នុងវិធាន ៦៣(៣)(ក)នៃវិធានផ្ទៃក្នុងថាបានបំពេញ ហើយនៅតែបានបំពេញដដែល ដែលជាហេតុធ្វើឱ្យ អបជ ជឿថាវាមានយុត្តិកម្មក្នុងការបន្តការឃុំខ្លួនលើភាគីដែលប្តឹងឧទ្ធរណ៍បន្ថែមទៀត។

### *ខ. ការឃុំខ្លួនបណ្តោះអាសន្ននៅតែជាវិធានការចាំបាច់ - វិធាន ៦៣(៣)(ខ)*

24. ក្រោយពីធ្វើការពិនិត្យរាល់ភស្តុតាងទាំងអស់ដែលមាននៅក្នុងសំណុំរឿងនៅពេលនោះ អបជ បានចេញសាលដីកានៅថ្ងៃទី១១ ខែឧសភា ឆ្នាំ២០០៩ ដោយបានសម្រេចថា ការឃុំខ្លួនបណ្តោះអាសន្ននៅក្នុងមន្ទីរឃុំឃាំង អ.វ.ត.ក ជាវិធានការចាំបាច់។ អបជ បានសម្រេចថា ការឃុំខ្លួនបណ្តោះអាសន្នជាវិធានការចាំបាច់ អនុលោមតាមវិធាន ៦៣(៣)(ខ)នៃវិធានផ្ទៃក្នុង ក្នុងការ (១) រារាំងកុំឱ្យជនត្រូវចោទគាបសង្កត់ទៅលើសាក្សី ឬ ជនរងគ្រោះ (២) ថែរក្សាភស្តុតាង (៣) ធានាអំពីវត្តមានរបស់ជនត្រូវចោទនៅក្នុងដំណើរការនីតិវិធី និង (៤) រក្សាសណ្តាប់ធ្នាប់សាធារណៈ[39]។

25. ចាប់តាំងពីថ្ងៃទី១១ ខែឧសភា ឆ្នាំ២០០៩ ដើមបណ្តឹងឧទ្ធរណ៍មិនបានផ្តល់នូវភស្តុតាងណាមួយដែលអាចឱ្យ អបជ ច្រានចោលសេចក្តីសម្រេចរបស់ខ្លួនឡើយ។ សហព្រះរាជអាជ្ញាសូមលើកឡើងថា សំអាងហេតុដូចបានលើកឡើងនៅក្នុងសាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួន

---

[37] (ត្រូវបានលុបចេញ)

[38] (ត្រូវបានលុបចេញ)

[39] សាលដីកា អ.ប.ជ លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នលើកទី១ កថាខណ្ឌ៤៥។

នៅតែមានសុពលភាពមកទល់ថ្ងៃនេះ ហើយសំអាងហេតុនេះគួរតែទុកជាបានការដដែល។ បន្ថែមលើចំនុចនេះ ក្រុមមេធាវីការពារក្តីមិនបានលើកឡើងទឡ្ហីករណ៍ទាំងឡាយដែលមានភាពត្រឹមត្រូវដើម្បីយកមកតវ៉ាចំពោះអត្ថិភាពនៃលក្ខខណ្ឌតម្រូវផ្សេង ដូចមានចែងនៅក្នុងវិធាន៦៣(៣)(ខ) នៃវិធានផ្ទៃក្នុង។ ដូច្នេះ សហព្រះរាជអាជ្ញាបានដាក់បញ្ចូលជាចំនុចយោងនូវការលើកឡើងនៅក្នុងកថាខណ្ឌទី៤៥ ដល់ កថាខណ្ឌទី ៥៣ នៃ "សេចក្តីសន្និដ្ឋានតបរបស់ខ្លួនចំពោះបណ្តឹងឧទ្ធរណ៍របស់ក្រុមមេធាវីការពារក្តីទៅនឹងដីកាឃុំខ្លួនបណ្តោះអាសន្នចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៨" ហើយនឹងផ្តោតលើតែបញ្ហាទាំងឡាយមួយចំនួន ឬក៏ធាតុផ្សំថ្មីៗតែប៉ុណ្ណោះ[40]។

### ***ហានិភ័យនៃការរត់គេចខ្លួន***

26. ក្រុមមេធាវីការពារក្តីបានលើកឡើងទឡ្ហីករណ៍តបមកវិញតែមួយប៉ុណ្ណោះគឺ ស្ថានភាពនៅពេលនេះមានលក្ខណៈខុសពីមុន ពីព្រោះស្ថានភាពសុខភាពរបស់ដើមបណ្តឹងឧទ្ធរណ៍បានចុះខ្សោយក្នុងរយៈពេលមួយឆ្នាំមុននេះ ដែលវាធ្វើឱ្យហានិយភ័យនៃការរត់គេចខ្លួននេះមានលក្ខណៈតិចតួចស្តួចស្តើង។ ក្រុមមេធាវីការពារក្តីបានផ្តល់មូលដ្ឋានគាំទ្រលើការលើកឡើងរបស់ខ្លួនដោយយោងលើ **(ត្រូវបានលុបចេញ)** [41] **(ត្រូវបានលុបចេញ)** [42] ដែលសហចៅក្រមស៊ើបអង្កេតបានចេញដីកាបង្គាប់ចាត់តាំង[43]។ ក្រោយពីស្នើសុំរបាយការណ៍នេះពីសហចៅក្រមស៊ើបអង្កេត សហព្រះរាជអាជ្ញាទទួលបានការជូនដំណឹងអំពីរបាយការណ៍នេះ នៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៨។ យើងមិនអាចធ្វើការសន្និដ្ឋានចេញពីរបាយការណ៍នេះចំពោះការចោទប្រកាន់ថាសុខភាពរបស់ជនត្រូវចោទមានការចុះថយនោះឡើយ។ **(ត្រូវបានលុបចេញ)**

---

[40] *រឿងក្តី អៀង ធីរិទ្ធ,* ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់លោកស្រី អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៨, ចុះថ្ងៃទី៩ ខែមករា ឆ្នាំ២០០៩, ឯកសារ C20/5/7, ERN 00270423-49 (ភាសាអង់គ្លេស)។

[41] **(ត្រូវបានលុបចេញ)**

[42] **(ត្រូវបានលុបចេញ)**

[43] **(ត្រូវបានលុបចេញ)**

00424672



[44]។ មិនមានចំនុចណាមួយនៅក្នុងរបាយការណ៍នេះបានលើកឡើងថា សុខភាពរបស់ជនត្រូវចោទនឹងរារាំងការរត់គេចខ្លួនរបស់គាត់ មិនថាមានឬក៏គ្មានការជួយជ្រោមជ្រែងនោះទេ។ (ត្រូវបានលុបចេញ)

[45] (ត្រូវបានលុបចេញ) [46]។

***ហានិភ័យនៃការគាបសង្កត់ទៅលើសាក្សី និង ជនរងគ្រោះ***

27. នៅក្នុងសាលដីការបស់ខ្លួន អបជ បានសម្រេចថា ជនត្រូវចោទមានលទ្ធភាពពិនិត្យលើភស្តុតាងតាមរយៈមេធាវីការពារក្តីរបស់ខ្លួន ដែលភស្តុតាងទាំងនោះមានព័ត៌មានពិស្តារស្តីពីតួនាទីរបស់គាត់

---

[44] (ត្រូវបានលុបចេញ)

[45] (ត្រូវបានលុបចេញ)

[46] (ត្រូវបានលុបចេញ)

នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ដូច្នេះវានៅតែមានភាពចាំបាច់ក្នុងការឃុំខ្លួនគាត់ជាបណ្ដោះអាសន្ន ដើម្បីជៀសវាងកុំឱ្យគាត់ធ្វើការគាបសង្កត់ទៅលើសាក្សី ឬជនរងគ្រោះ និងដើម្បីរារាំងគាត់កុំឱ្យបំផ្លាញភស្តុតាង។ អាកប្បកិរិយាអតីតកាលរបស់គាត់ និងសេចក្ដីថ្លែងការណ៍ជាសាធារណៈរបស់ភាគី ដែលប្ដឹងឧទ្ធរណ៍ដូចបានលើកឡើងនៅក្នុងសាលដីការបស់ អបជ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០០៩ សម្រេចលើបណ្ដឹងឧទ្ធរណ៍[47] បានបង្ហាញយ៉ាងច្បាស់អំពីហានិយភ័យជាក់ស្ដែងដែលអាចឱ្យជនត្រូវចោទគាបសង្កត់ បំភិតបំភ័យ ឬជ្រៀតជ្រែកលើសាក្សី ឬជនរងគ្រោះ ប្រសិនបើដោះលែងគាត់ឱ្យមានសេរីភាពជាបណ្ដោះអាសន្ននោះ។ ដើមបណ្ដឹងឧទ្ធរណ៍មានលទ្ធភាពពិនិត្យមើលឈ្មោះរបស់សាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណីសំខាន់ៗ ដែលអ្នកទាំងអស់នេះមិនទាន់បានផ្ដល់សក្ខីកម្មជូនសហចៅក្រមស៊ើបអង្កេតនៅឡើយនៅក្នុងដំណាក់កាលនេះ ឬមិនទាន់បានផ្ដល់សក្ខីកម្មរហូតដល់ពេលបិទការស៊ើបអង្កេត និងរហូតដល់ពេលបណ្ដឹងឧទ្ធរណ៍ចំបងៗទាំងអស់ដែលបានប្ដឹងនៅចំពោះមុខ អបជ បានសម្រេចជាស្ថាពរ អនុលោមតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង[48]។ ម្យ៉ាងវិញទៀត សាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណីទាំងនេះមួយចំនួននឹងមកផ្ដល់សក្ខីកម្មនៅចំពោះមុខ អជសង នៅក្នុងពេលជំនុំជម្រះ ប្រសិនជនត្រូវចោទត្រូវបានចោទប្រកាន់បញ្ជូនទៅ

---

[47] សាលដីកា អ.ប.ជ លើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្នជនត្រូវចោទ អៀង ធីរិទ្ធ, ឯកសារ C20/I/26, ERN 00201588-604 (ភាសាអង់គ្លេស) ត្រង់កថាខណ្ឌ៤៩-៥០។ លោកស្រី អៀង ធីរិទ្ធ បានជេប្រមាថ និងប៉ុនប៉ងគំរាម លោក ឆាំង យុះ លិខិតផ្ញើចេញចុះថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ១៩៩៩ ដោយលោកស្រី អៀង ធីរិទ្ធ ទៅកាន់ Chris Decherd, ត្រូវបានបោះផ្សាយក្រោមចំណងជើងថា "អៀង ធីរិទ្ធ និយាយថារូបគាត់គ្រាន់តែចង់បម្រើប្រជាជនរបស់គាត់តែប៉ុណ្ណោះ", សារព័ត៌មាន *The Cambodia Daily*, ចេញផ្សាយថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ១៩៩៩, ERN 00000588-89 (ភាសាអង់គ្លេស)។ ជនត្រូវចោទត្រូវបានរាយការណ៍មកថា បានឲ្យមនុស្សបិតមាត់ ម៉ី ម៉ាក់ (May Makk) នៅក្នុងកិច្ចប្រជុំ DNUM ក្នុងឆ្នាំ២០០៣៖ "Khmer Rouge Inc: Former Communists Embrace the Market Economy in Malai District," *សារព័ត៌មាន The Cambodia Daily*, ចេញផ្សាយថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៧, ERN 00106073-78។

[48] វិធាន៦៦(១) នៃវិធានផ្ទៃក្នុងចែងថា បន្ទាប់ពីការជូនដំណឹងដោយសហចៅក្រមស៊ើបអង្កេតអំពីការបញ្ចប់ការស៊ើបអង្កេត ភាគីទាំងឡាយមានរយៈពេល១៥ថ្ងៃដើម្បីធ្វើការស្នើសុំកិច្ចស៊ើបសួរបន្ត ដែលអាចរួមមានទាំងសំណើធ្វើការស្ដាប់ចម្លើយសាក្សី ឬ ដើមបណ្ដឹងរដ្ឋប្បវេណីដែលមិនត្រូវបានស្ដាប់ចម្លើយដោយសហចៅក្រមស៊ើបអង្កេត ឬ ធ្វើការស្ដាប់ចម្លើយសាក្សី/ដើមបណ្ដឹងរដ្ឋប្បវេណីឡើងវិញ។ វិធាន៦៦(២) នៃវិធានផ្ទៃក្នុងចែងថា ប្រសិនបើសហចៅក្រមស៊ើបអង្កេតសម្រេចបដិសេធសំណើទាំងនោះ ពួកគេត្រូវចេញសេចក្ដីបង្គាប់ដោយមានសំអាងហេតុ ដែលអាចអនុវត្តបាននៅចំពោះមុខ អ.ប.ជ ក្នុងរយៈពេល ៣០ថ្ងៃ (វិធាន៦៦(៣)នៃវិធានផ្ទៃក្នុង)។ វាមានន័យថា សាក្សី និង ដើមបណ្ដឹងរដ្ឋប្បវេណីជាសក្ដានុពលនៅតែអាចត្រូវបានស្ដាប់ចម្លើយដោយសហចៅក្រមស៊ើបអង្កេត បន្ទាប់ពីទទួលបានសំណើមួយទាក់ទងនឹងកិច្ចស៊ើបសួរបន្ត ឬ ជាលទ្ធផលនៃសេចក្ដីសម្រេចរបស់ អ.ប.ជ លើបណ្ដឹងឧទ្ធរណ៍។ ដូច្នេះ អ.ប.ជ ត្រូវបាន ស្នើសុំឱ្យសន្និដ្ឋានសរុបថា មេធាវីការពារក្ដីបំភ័ន្ត អ.ប.ជ ដោយអះអាងថា "ការបិទការស៊ើបសួរមានន័យថា នឹងមិនមានការអះអាងថាវាចាំបាច់ដើម្បីឃុំខ្លួនជនត្រូវចោទ ដើម្បីធានាដល់សេចក្ដីសុច្ចរិតនៃការស៊ើបសួរនោះទេ" (បណ្ដឹងឧទ្ធរណ៍, កថាខណ្ឌ៤)។

00424674



ធ្វើការជំនុំជម្រះមែននោះ។ យោងតាមចំនុចទាំងនេះ វាមានហានិយភ័យធំធេងជាងនេះ ប្រសិនបើដោះលែងជនត្រូវចោទឱ្យមានសេរីភាពជាបណ្តោះអាសន្ន ពីព្រោះជនត្រូវចោទរូបនេះអាចមានឥទ្ធិពលលើសាក្សី ឬជនរងគ្រោះ ដើម្បីកុំឱ្យមកធ្វើការផ្តល់សក្ខីកម្មនៅចំពោះមុខ អ.វ.ត.ក។ បន្ថែមលើចំនុចនេះ ប្រសិនបើដោះលែងជនជនត្រូវចោទឱ្យមានសេរីភាពជាបណ្តោះអាសន្ន វានឹងមានហានិយភ័យយ៉ាងពិតប្រាកដ ដែលអាចឱ្យដើមបណ្តឹងឧទ្ធរណ៍នេះបន្តធ្វើសេចក្តីថ្លែងការណ៍មិនសមរម្យដល់សារព័ត៌មានជាសាធារណៈ ដែលចំនុចនេះនឹងមានអានុភាពបំភិតបំភ័យដល់សាក្សី និងជនរងគ្រោះ ហើយថែមទាំងធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈទៀតផង។

28. អបជ ក៏បានកត់សម្គាល់ឃើញដែរថា អាកប្បកិរិយាគម្រាមកំហែង និងបំភិតបំភ័យដល់ភាគី និង/ឬចៅក្រមក្នុងពេលសវនាការនៅចំពោះមុខ អបជ នាថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០០៩ ដែលនៅពេលនោះជនត្រូវចោទបានស្រែកប្រកាសថា៖ “ដូច្នេះ កុំចោទខ្ញុំពីបទឃាតកម្ម ប្រយ័ត្នធ្លាក់នរកប្រាំពីរជាន់”[49]។ ហេតុការណ៍នេះកើតចេញក្រោយពីការគម្រាមកំហែង និងការជេរប្រមាថស្រដៀងគ្នា ដែលបានកើតឡើងនៅក្នុងសវនាការថ្ងៃទី២១ ខែឧសភា និង ថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០០៩ ដូចដែលបានលើកឡើង នៅក្នុងសេចក្តីសន្និដ្ឋានតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍ចំពោះការបន្តថិរវេលាលើការឃុំខ្លួនបណ្តោះអាសន្នលើកដំបូង ហើយនឹងអាកប្បកិរិយា និងសេចក្តីថ្លែងការណ៍ហិង្សាទាំងឡាយដែលបានធ្វើឡើងជាសាធារណៈ[50]។ ចាប់តាំងពីពេលនោះមក យើងឃើញមានហេតុការណ៍ជាច្រើនទៀត **(ត្រូវបានលុបចេញ**

[49] សាលដីកា អ.ប.ជ លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទ អៀង ធីរិទ្ធ, ឯកសារ C20/I/26, ERN 00201588-604 (ភាសាអង់គ្លេស) ត្រង់កថាខណ្ឌ៤១ និង ៤២។

[50] *រឿងក្តី អៀង ធីរិទ្ធ,* ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់លោកស្រី អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៨, ចុះថ្ងៃទី៩ ខែមករា ឆ្នាំ២០០៩, ឯកសារ C20/5/7, ERN 00270423-0449 (ភាសាអង់គ្លេស), កថាខណ្ឌ ៤៧-៤៩ និង ៥០។

51។

29. ហេតុការណ៍មួយទៀតបានកើតឡើងក្នុងពេលដែល (ត្រូវបានលុបចេញ)

52។ (ត្រូវបានលុបចេញ)

ឥរិយាបថមាក់ងាយ បែបនេះរបស់ជនត្រូវចោទ ដូចជា ការគម្រាមកំហែង និងការប៉ុនប៉ងបំភិតបំភ័យភាគីទាំងឡាយ នៅក្នុងពេលធ្វើសវនាការ ឬនៅក្នុងមន្ទីរឃុំឃាំង បានផ្តល់ជាភស្តុតាងបន្ថែមជាមូលដ្ឋានគាំទ្រដល់ហានិយភ័យចំពោះការគាបសង្កត់ ដែលភាគីប្តឹងឧទ្ធរណ៍នេះអាចប្រព្រឹត្តទៅលើសាក្សី ឬជនរងគ្រោះ ប្រសិនបើដោះលែងជនត្រូវចោទរូបនេះជាបណ្តោះអាសន្ន។

***វិធានការចាំបាច់ក្នុងការរក្សាសណ្តាប់ធ្នាប់សាធារណៈ***

30. ចំពោះការគម្រាមកំហែងដល់សណ្តាប់ធ្នាប់សាធារណៈវិញ ក្រុមមេធាវីការពារក្តីបានតវ៉ាថា វត្តមាននៃជំងឺបាត់ស្បាត មិនអាចនាំឱ្យមានការសន្និដ្ឋានថានឹងធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈឡើយ ប្រសិនបើដោះលែងជនត្រូវចោទឱ្យមានសេរីភាពជាបណ្តោះអាសន្ននោះ។ ក្រុមមេធាវីការពារក្តីបានលើកឡើងនូវអត្ថបទមួយដែល Rob Savage បានលើកឡើងអំពីជំងឺបាក់ស្បាត តែមិនបានលើកឡើងទឡ្ហីករណ៍ និងអត្ថបទដទៃៗទៀត ដែលសហព្រះរាជអាជ្ញាបានលើកឡើងនៅក្នុងសេចក្តីសន្និដ្ឋានទាំងឡាយរបស់ខ្លួនកាលពីលើកមុនអំពីជំងឺបាក់ស្បាត បញ្ហាសុខភាពស្មារតី និងអំពើហិង្សាដែលអាចកើតឡើងចំពោះអតីតមេដឹកនាំខ្មែរក្រហម ប្រសិនបើដោះលែងជនត្រូវចោទ[53]។ បន្ថែមពីនេះ ចាប់តាំងពីថ្ងៃទី១១ ខែឧសភា ឆ្នាំ២០០៩ ក្រុមមេធាវីការពារក្តីមិនបានលើកភស្តុតាងដែលធ្វើឱ្យតុលាការជឿថា វាគ្មានការគម្រាមកំហែងដល់សណ្តាប់ធ្នាប់សាធារណៈឡើយ ប្រសិន

---

[51] (ត្រូវបានលុបចេញ)

[52] (ត្រូវបានលុបចេញ)

[53] *រឿងក្តី អៀង ធីរិទ្ធ,* ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់លោកស្រី អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៨, ចុះថ្ងៃទី៩ ខែមករា ឆ្នាំ២០០៩, ឯកសារ C20/5/7, ERN 00270423-0449 (ភាសាអង់គ្លេស), កថាខណ្ឌ៥២។

បើដោះលែងជនត្រូវចោទ។ ហេតុដូច្នេះ សហព្រះរាជអាជ្ញាសូមដាក់ជូនថា សំអាងហេតុនៅក្នុងសាលដីកាសម្រេចលើបណ្ដឹងឧទ្ធរណ៍ ស្ដីពីការបន្តថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នលើកដំបូងនៅតែមានសុពលភាព ហើយសំអាងហេតុនេះគួរតែតម្កល់ទុកជាបានការដដែល។ ម្យ៉ាងវិញទៀត ក្រុមមេធាវីការពារក្ដីបានយោងលើសក្ខីកម្មរបស់អ្នកជំនាញបណ្ឌិត **ឈឹម សុធារ៉ា** នៅក្នុងពេលសវនាការជំនុំជម្រះលើរឿងក្ដីលោក **កាំង ហ្គេកអ៊ាវ** ហៅ **ឌុច** នៅថ្ងៃទី២៥ ខែសីហា ឆ្នាំ២០០៩ (សំណុំរឿងលេខ ០០១) ដែលនៅពេលនោះ អ្នកជំនាញរូបនេះមិនត្រឹមតែបានផ្ដល់សក្ខីកម្មអំពីជំងឺបាក់ស្បាតប៉ុណ្ណោះទេ លោកថែមទាំងបានលើកឡើងអំពីផលវិបាកផ្នែកចិត្តសាស្ត្រដែលកើតឡើងលើជនរងគ្រោះ និងជំងឺប៉ះទង្គិចផ្លូវចិត្តរបស់ពួកគេផងដែរ[54]។ ជាពិសេស អ្នកជំនាញរូបនេះបានលើកឡើងថា ជនរងគ្រោះដែលទទួលរងជំងឺប៉ះទង្គិចផ្លូវចិត្ត បានទទួលរងនូវការធ្លាក់ទឹកចិត្ត ការខឹងសម្បារ សុរាសោណ្ឌរោគ និងអំពើហិង្សាក្នុងគ្រួសារ[55]។ អ្នកជំនាញបានសង្កត់ធ្ងន់ថា ការជាសះស្បើយពីជំងឺចិត្តសាស្ត្ររបស់ជនរងគ្រោះនៅក្នុងសម័យខ្មែរក្រហម វាអាស្រ័យទៅលើភាពស្មោះត្រង់ ការសម្ដែងចេញ និងការទទួលស្គាល់របស់អតីតមេដឹកនាំខ្មែរក្រហម។ ការបដិសេធ និងការមិនព្រមទទួលខុសត្រូវគឺជាបន្ទុកមួយទៀតដល់ជនរងគ្រោះ និងប្រជាពលរដ្ឋកម្ពុជាទាំងមូល ហើយជនរងគ្រោះ នឹងបាត់បង់នូវសេចក្ដីសប្បាយចិត្ត ហើយនឹងមានអារម្មណ៍ខឹងសម្បារចំពោះការបដិសេធបែបនេះ[56]។ វាពុំមានភាពចាំបាច់ក្នុងការលើកឡើងវិញអំពីករណីដែលជនត្រូវចោទតែងតែបដិសេធថា ខ្លួនពុំបានប្រព្រឹត្តឧក្រិដ្ឋកម្មទាំងឡាយដែលបានចោទប្រកាន់លើខ្លួន។ អ្នកជំនាញ **ឈឹម សុធារ៉ា** ក៏បានផ្ដល់សក្ខីកម្មផងដែរថា ដោយសារការជំនុំជម្រះនេះហើយ វាបានធ្វើឱ្យជំងឺប៉ះទង្គិចផ្លូវចិត្តរបស់ជនរងគ្រោះមួយចំនួនបានរើឡើងវិញ[57]។ ម្យ៉ាងវិញ

---

[54] ប្រតិចារិកកំណើការនីតិវិធីជំនុំជម្រះក្ដី កាំង ហ្គេកអ៊ាវ ហៅ "ឌុច", ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០០៩, ឯកសារ E1/68.1, ERN 00370950-1055 (ភាសាអង់គ្លេស)។

[55] ប្រតិចារិកកំណើការនីតិវិធីជំនុំជម្រះក្ដី កាំង ហ្គេកអ៊ាវ ហៅ "ឌុច", ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០០៩, ឯកសារ E1/68.1, sp. ទំព័រ១៥-១៦/៩២, ERN 00370967-68/94 (ភាសាអង់គ្លេស)

[56] ប្រតិចារិកកំណើការនីតិវិធីជំនុំជម្រះក្ដី កាំង ហ្គេកអ៊ាវ ហៅ "ឌុច", ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០០៩, ឯកសារ E1/68.1, ទំព័រ៣៨, ERN 00370990 (ភាសាអង់គ្លេស)។

[57] ប្រតិចារិកកំណើការនីតិវិធីជំនុំជម្រះក្ដី កាំង ហ្គេកអ៊ាវ ហៅ "ឌុច", ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០០៩, ឯកសារ E1/68.1, ទំព័រ១៨ និង ៥៩, ERN 00370970 និង 00371011 (ភាសាអង់គ្លេស)។ សូមមើលផងដែរអត្ថបទមានចំណងជើងថា *Pour une meilleure justice, il faut aussi un soutien psychologique aux victimes*, សារព័ត៌មាន Cambodge soir, ដោយ ឈាង បុប្ផា (Chheang Bopha), ចេញផ្សាយថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០០៦, មើលនៅhttp://www.cambodgesoir.info/index.php?option=com_content&view=article&catid=43%3Aarchives&id=20365%3Apour-une-meilleure-justice-il-faut-aussi-un-soutien-psychologique-aux-victimes&Itemid=46 ។

ទៀត "តាមរបាយការណ៍ មានប្រជាពលរដ្ឋប្រមាណ៣០% នៃប្រជាពលរដ្ឋកម្ពុជាជិត១៤លាននាក់ បានទទួលរងនូវការចុះខ្សោយខាងសតិស្មារតី ដូចជាការថប់អារម្មណ៍ និងការឈឺចាប់ខាងផ្លូវកាយជាប្រចាំដែលមិនអាចពន្យល់បាន ភាពធឹងធោងអារម្មណ៍មិនអាចដឹងមុនបាន និងការផ្ទុះចេញនូវទោសៈមួយរំពិច"[58]។ ជនរងគ្រោះមួយចំនួនធំបានចម្លងជំងឺប៉ះទង្គិចផ្លូវចិត្តពីមួយជំនាន់ទៅមួយជំនាន់ទៀត[59]។ នៅក្នុងដំណាក់កាលនេះ ដែលកិច្ចស៊ើបសួររៀបនឹងបញ្ចប់ ហើយប្រជាពលរដ្ឋកំពុងទន្ទឹងរង់ចាំដំណាក់កាលជំនុំជម្រះ ប្រសិនបើដោះលែងជនត្រូវចោទ វានឹងមានហានិភ័យពិតប្រាកដមួយ ដែលធ្វើឱ្យបញ្ហាផ្លូវអារម្មណ៍នេះកាន់តែដុនដាបចុះ ហើយនឹងបង្កឱ្យមានការរំជើបរំជួលនូវអំពើហិង្សា។

31. ហេតុដូច្នេះ សហព្រះរាជអាជ្ញាស្នើសុំឱ្យ អបជ សម្រេចថា លក្ខខណ្ឌនៃការឃុំខ្លួន ដូចមានចែងនៅក្នុងវិធាន ៦៣(៣)(ខ)(i)-(v) នៃវិធានផ្ទៃក្នុង បានបំពេញ ហើយនៅតែបានបំពេញដដែល ដែលជាហេតុធ្វើឱ្យ អបជ យល់ឃើញថា វាមានយុត្តិកម្មក្នុងការបន្តថិរវេលានៃការឃុំខ្លួនភាគីដែលប្ដឹងឧទ្ធរណ៍នេះ បណ្ដោះអាសន្ន។

### *គ. មិនចាំបាច់មានដីកាសម្រេចឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការ*

32. អបជ បានសម្រេចនៅថ្ងៃទី១១ ខែឧសភា ឆ្នាំ២០០៩ ថា ការបន្តឃុំខ្លួនជនត្រូវចោទនៅមានភាពចាំបាច់ អនុលោមតាមវិធាន ៦៣(៣) នៃវិធានផ្ទៃក្នុង ដោយសារមិនមានហេតុផលណាមួយដែល "គាំទ្រលើសំណើសុំឱ្យសម្រេចដោះលែងឱ្យមានសេរីភាព" ដោយដាក់ឱ្យស្ថិតនៅក្រោមការត្រួត

---

អត្ថបទសារព័ត៌មានមានចំណងជើងថា Now Prozac Battles Dark Dreams That Khmer Rouge Left, The សារព័ត៌មាន New York Times, ព្រឹត្តិប័ត្រព័ត៌មាន Phnom Penh, ចេញផ្សាយថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០៦, មើលនៅ http://www.nytimes.com/2006/02/16/international/asia/16cambodia.html?_r=1&pagewanted=print, ដែលលោក ឈឹម សុធារា (Chhim Sotheara) "និយាយថា ការខ្វល់ខ្វាយរបស់គាត់គឺ "ការធ្វើឲ្យមានការប៉ះទង្គិចផ្លូវចិត្តឡើងវិញ (retraumatization)" របស់អ្នករួចជីវិត ដែលនឹងប្រឈមមុខនឹងអតីតកាល។ ការប៉ះទង្គិចផ្លូវចិត្តថ្មីទៅលើមនុស្សជំនាន់ក្រោយ ដែលមិនបានឆ្លងកាត់សម័យខ្មែរក្រហម" និងធ្វើឲ្យមានកំហឹងឡើងវិញ និងអរិភាពក្នុងចំណោមជនរងគ្រោះ" ។

[58] អត្ថបទសារព័ត៌មានចំណងជើងថា *Cambodia's long look backwards; doctors struggle to heal troubled country*, សារព័ត៌មាន AFP, ចេញផ្សាយថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០០៧, មើលនៅ http://afp.google.com/article/ALeqM5idAIOjK3ixMBq5JqFvuqDOZaRtcg?index=0

[59] អត្ថបទមានចំណើងថា *Des psychiatres au secours des victimes enferm"s dans leurs cauchemars*, សារព័ត៌មាន Cambodge Soir, ចេញផ្សាយថ្ងៃទី១១ ខែមីនា ឆ្នាំ2005 មើលនៅ http://www.cambodgesoir.info/index.php?view=article&catid=43:archives&id=16087:des-psychiatres-au-secours-des-vicitmes-enfermees-dans-leurs-cauchemars&format=pdf&option=com_content

ពិនិត្យរបស់តុលាការ។ ភាពចាំបាច់ក្នុងការឃុំខ្លួនបណ្ដោះអាសន្នមានអាទិភាពជាងលក្ខខណ្ឌទាំងឡាយស្ដីពីការឃុំខ្លួន[60]។ ដូចដែលបានផ្ដល់ទឡ្ហីករណ៍ខាងលើ ដោយសារភាពចាំបាច់ក្នុងការឃុំខ្លួនបណ្ដោះអាសន្នមិនមានការថយចុះ ដូច្នេះលក្ខខណ្ឌទាំងឡាយស្ដីពីការឃុំខ្លួនមិនអាចទទួលយកបាន។ ចាប់តាំងពីថ្ងៃទី១១ ខែឧសភា ឆ្នាំ២០០៩ ក្រុមមេធាវីការពារក្ដីមិនបានផ្ដល់ភស្ដុតាងណាមួយដែលអាចឱ្យ អបជ ច្រានចោលសេចក្ដីសម្រេចរបស់ខ្លួនថាឥតបានការឡើយ។

33. សហព្រះរាជអាជ្ញាសូមលើកឡើងថា សំអាងហេតុដូចមានចែងនៅក្នុងសាលដីកាលើបណ្ដឹងឧទ្ធរណ៍ចំពោះការបន្តចិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នលើកទី១ មានសុពលភាព ហើយនៅតែបន្តមានសុពលភាពដដែល។ ហេតុដូច្នេះ សហព្រះរាជអាជ្ញាសូមស្នើឱ្យ អបជ បដិសេធចោលសំណើសុំឱ្យដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការ ហើយតម្កល់ទុកលក្ខខណ្ឌទាំងឡាយនៃការឃុំខ្លួនទុកជាបានការ ដោយច្រានចោលលក្ខខណ្ឌដទៃទៀត។

## IV. សេចក្ដីសន្និដ្ឋាន

34. ហេតុដូច្នេះ សហព្រះរាជអាជ្ញាសូមស្នើឱ្យ អបជ ច្រានចោលបណ្ដឹងឧទ្ធរណ៍របស់មេធាវីការពារក្ដីទុកជាឥតបានការ។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី០៨ ខែមករា ឆ្នាំ២០១០ | លោកស្រី ជា លាង<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | [signature] |
| | លោក William SMITH<br>សហព្រះរាជអាជ្ញារង | អាដឺឡែត | |

[60] សាលដីកាលើបណ្ដឹងឧទ្ធរណ៍អំពីការបន្តចិរវេលាលើកទីមួយ, កថាខណ្ឌ៦៨ - ៦៩។